00233005

C22/I/74

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

*តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៣)

| | |
|---|---|
| **ចំពោះមុខ:** | **ចៅក្រម ប្រាក់ គឹមសាន ប្រធាន** |
| | **ចៅក្រម Rowan DOWNING** |
| | **ចៅក្រម នីយ ថុល** |
| | **ចៅក្រម Katinka LAHUIS** |
| | **ចៅក្រម ហួត វុទ្ធី** |
| **ក្រឡាបញ្ជីសវនាការ** | **ឌួន សុរាសី** |
| | **Dirk Jan LAMAN** |
| **កាលបរិច្ឆេទ:** | **១៧ តុលា ២០០៨** |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 17 / 10 / 2008
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fry

---

**សាធារណៈ**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្តោះអាសន្ន**

---

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 17 / 10 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fry

**ការិយាល័យសហព្រះរាជអាជ្ញា**

**ជា លាង**
**Robert PETIT**
**យ៉េត ចរិយា**
**William SMITH**
**តាន់ សេណារ៉ុង**
**Anees AHMED**

**ជនត្រូវចោទ**

**អៀង សារី**

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ធី
គង់ ពិសី
Silke STUDZINSKY
យ៉ុង ផានិត
គឹម ម៉េងឃី
Martine JACQUIN

**សហមេធាវីការពារក្តី**

អាង ឧត្តម
Michael G. KARNAVAS

00233006





**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "**អ.វ.ត.ក**" ទទួលបានបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនលោក **អៀង សារី** បណ្ដោះអាសន្ន ("បណ្ដឹងឧទ្ធរណ៍")។

## ជំពូក ១ - សេចក្ដីផ្ដើម

១. អង្គបុរេជំនុំជម្រះ យោងទៅលើរបាយការណ៍ស្ដីពីការត្រួតពិនិត្យសំណុំរឿង អនុម័តកាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៨ លើនីតិវិធី អង្គច្បាប់ និងអង្គហេតុក្នុងសំណុំរឿងនេះ ដែលជាផ្នែកមួយនៃសាលដីកានេះ។[១]

២. នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានចេញដីកាកំណត់ថ្ងៃបើកសវនាការគឺថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨។[២]

៣. មុនថ្ងៃសវនាការ អង្គបុរេជំនុំជម្រះបានទទួលសំណុំរឿង ដែលត្រូវបានធ្វើបច្ចុប្បន្នភាពរួច។

៤. អង្គបុរេជំនុំជម្រះបានរៀបចំសវនាការជាសាធារណៈនៅថ្ងៃទី៣០ ខែមិថុនា ថ្ងៃទី១ ថ្ងៃទី២ និងថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៨។

៥. នៅក្នុងថ្ងៃសវនាការដំបូងគឺនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានស្ដាប់បញ្ហាបឋម ដែលសហមេធាវីការពារក្ដី និងសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើង។[៣] នៅក្នុងថ្ងៃទី១ ថ្ងៃទី២ និងថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានស្ដាប់សេចក្ដីសន្និដ្ឋានលើបញ្ហាយុត្តាធិការ និងបញ្ហាឃុំខ្លួនបណ្ដោះអាសន្ន។

---

[១] របាយការណ៍ស្ដីពីការត្រួតពិនិត្យ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៨ C22/I/42។

[២] ដីកាកំណត់ថ្ងៃសវនាការ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៨ C22/I/31។

[៣] សូមអាន សេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរនៃសេចក្ដីសម្រេចដោយផ្ទាល់មាត់ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ ស្ដីពីសំណើរបស់សហមេធាវី សុំពន្យារពេលសវនាការស្ដីពីបញ្ហាយុត្តាធិការ ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៨ C22/I/49 និងសេចក្ដីសម្រេចស្ដីពីបញ្ហាបឋម ដែលមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើង នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ចំពោះដីកាបង្គាប់ការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៨ C22/I/46។

៦. អង្គបុរេជំនុំជម្រះបានសម្រេចនៅក្នុងសេចក្តីសម្រេច និងសេចក្តីបង្គាប់ដោយឡែក លើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង។[៤]

៧. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ដើម្បីធានាកុំឱ្យប៉ះពាល់ដល់ការស៊ើបអង្កេត សាលដីកានេះនឹងប្រកាសជាសាធារណៈ ដោយចាំបាច់លុបចោលផ្នែកមួយចំនួន។

## ជំពូក ២ - ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

៨. នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៧ សហមេធាវីការពារក្តីរបស់ជនត្រូវចោទ បានដាក់សេចក្តីជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍ចំពោះដីកាបង្គាប់ការឃុំខ្លួនបណ្តោះអាសន្ន។ តាមរយៈដីកាបង្គាប់របស់ក្រឡាបញ្ជីនាយកចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៧ អង្គបុរេជំនុំជម្រះបានបង្គាប់ឱ្យសហមេធាវីការពារក្តី ដាក់សារណាជាលាយលក្ខណ៍អក្សររបស់ខ្លួនក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងអំពីដីកានេះ។ ដីកានេះបានជូនដំណឹងដល់ជនត្រូវចោទនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧។ នៅថ្ងៃទី៩ ខែមករា ឆ្នាំ២០០៨ សហមេធាវីការពារក្តីជនត្រូវចោទបានស្នើសុំអង្គបុរេជំនុំជម្រះ ឱ្យធ្វើការពន្យាររយៈពេលកំណត់ដាក់សារណាបណ្តឹងឧទ្ធរណ៍រហូតដល់ថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៨។ សំណើនេះបានទទួលការយល់ព្រមពីអង្គបុរេជំនុំជម្រះ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨។ សារណាបណ្តឹងឧទ្ធរណ៍បានដាក់នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៨ ហេតុដូច្នេះ សារណាបណ្តឹងឧទ្ធរណ៍បានដាក់ជូនមកទាន់ពេលវេលា ។

## ជំពូក ៣ - លក្ខណៈនៃបណ្តឹងឧទ្ធរណ៍

៩. បន្ទាប់ពីពិចារណាសេចក្តីសម្រេចរបស់ខ្លួននៅក្នុងរឿងក្តីមុនៗ[៥] និងសេចក្តីសន្និដ្ឋានរបស់ភាគីដូចដែលបានលើកឡើងនៅក្នុងរបាយការណ៍ស្តីពីការពិនិត្យសំណុំរឿង អង្គបុរេជំនុំជម្រះនឹងពិនិត្យមើលឡើងវិញលើដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន (“ដីកា”) ដោយធ្វើការពិនិត្យ:

[៤] សេចក្តីសម្រេចលើពាក្យសុំពិចារណាសារជាថ្មីស្តីពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះ ដោយខ្លួនឯង ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ C22/I/68 និង សេចក្តីបង្គាប់ដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាង ស្តីពីសិទ្ធិក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះ ដោយផ្ទាខ្លួនឯង ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៨ C22/I/69។

ក. ការអនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រុមស៊ើបអង្កេត ដោយគោរពតាមវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង។

ខ. ភាពគ្រប់គ្រាន់នៃអង្គហេតុ ក្នុងការចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ស្របតាមវិធាន៦៣(៣) នៃវិធានផ្ទៃក្នុង។

គ. ថាតើកាលៈទេសៈ ដែលដីកាបានយកមកធ្វើជាសម្អាង នៅមានអត្ថិភាពនាពេលបច្ចុប្បន្ន ដែរឬទេ។ និង

ឃ. ការឃុំខ្លួននៅក្នុងមន្ទីរពេទ្យ ដែលជាជម្រើសមួយបែបផ្សេងនៃការឃុំខ្លួនបណ្ដោះអាសន្ន។

## ជំពូក ៤ - ការអនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រុមស៊ើបអង្កេត ក្នុងការពិចារណា ការអនុវត្តន៍វិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង

### ១. មូលដ្ឋានច្បាប់សម្រាប់ធ្វើការពិនិត្យ

១០. បញ្ហាទីមួយ ដែលលើកឡើងនៅចំពោះមុខអង្គបុរេជំនុំជម្រះគឺថាតើ សហចៅក្រុមស៊ើបអង្កេតមានសមត្ថកិច្ចពិនិត្យបញ្ហានៃការកាត់ទោសកាលពីលើកមុន ឬព្រះរាជក្រឹត្យលើកលែងទោសដល់ជនត្រូវចោទ ដែរឬទេ។[៦]

១១. សហចៅក្រុមស៊ើបអង្កេតបានពិចារណាករណីនេះនៅក្នុងដីកាបង្គាប់ការឃុំខ្លួនបណ្ដោះអាសន្នដូចខាងក្រោម:

> "៥. មុនសម្រេចលើការឃុំខ្លួនបណ្ដោះអាសន្នរបស់ អៀង សារី យើងត្រូវរំលឹកអំពីស្ថានភាពពិសេសរបស់ជននេះ ដែលចោទជាបញ្ហាពិសេស ដែលសហចៅក្រុមស៊ើបអង្កេតមានកាតព្វកិច្ចរកភស្តុតាងដាក់បន្ទុក និង ដោះបន្ទុកត្រូវសម្រេច។ តាមរយៈសាលក្រមរបស់តុលាការបដិវត្តន៍នៅភ្នំពេញ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៩ អៀង សារី ត្រូវបានផ្ដន្ទាទោសប្រហារជីវិតដោយកំបាំងមុខ និងរឹបអូសទ្រព្យសម្បត្តិ ចំពោះបទល្មើសប្រល័យពូជសាសន៍។ ជាការជាក់ស្ដែង សាលក្រមនេះចូលជាស្ថាពរតាមច្បាប់កម្ពុជា។ បន្ទាប់មក អនុលោមតាមព្រះរាជក្រឹត្យចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៩៦ អៀង

---

[៥] សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ចំពោះដីកាបង្គាប់ការឃុំខ្លួនលោក នួន ជា បណ្ដោះអាសន្ន ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ C11/54 ("សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ចំពោះដីកាបង្គាប់ការឃុំខ្លួនលោក នួន ជា បណ្ដោះអាសន្ន")។

[៦] សូមអាន សាលក្រមរបស់តុលាការប្រជាជនបដិវត្ត ចុះខែសីហា ឆ្នាំ១៩៧៩ និងព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៦/៧២។

00233009

E22 / I 174



សារី បានទទួលការអនុគ្រោះទោសចំពោះការផ្តន្ទាទោស និងការលើកលែងទោសចំពោះច្បាប់ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៤ "ស្តីអំពីការដាក់ខ្មែរក្រហមឱ្យនៅក្រៅច្បាប់"។

៦. ក្នុងស្ថានភាពនេះចោទជាបញ្ហាផ្លូវច្បាប់មួយចំនួន៖ ជាបឋម តើការចោទប្រកាន់បច្ចុប្បន្ននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប៉ះពាល់ដល់អាជ្ញាអស់ជំនុំ ដោយអនុលោមតាមការអនុវត្តទ្រឹស្តីទូទៅ "*Ne bis in idem* ឬទេ? (ជនម្នាក់មិនអាចត្រូវបានចោទប្រកាន់ ឬផ្តន្ទាទោស ចំពោះបទល្មើសដែលត្រូវបានសម្រេចថាគ្មានទោស ឬផ្តន្ទាទោសរួចហើយនោះទេ?" ជាបន្តទៀត នៅពេលដែលមានចម្លើយអវិជ្ជមានចំពោះសំណួរទី១នេះ និងថាសហចៅក្រមស៊ើបអង្កេតមានសមត្ថកិច្ចដើម្បីសម្រេចលើវិសោលភាពនៃព្រះរាជក្រឹត្យឆ្នាំ១៩៩៦) តើការអនុគ្រោះទោស និងការលើកលែងទោសដល់ អៀង សារី អាចយកមកតតាំងបានចំពោះ ការចោទប្រកាន់នៅអង្គជំនុំជម្រះវិសាមញ្ញដែរឬទេ? យើងនឹងពិនិត្យមើលលើបញ្ហាទាំងនេះដូចខាងក្រោម។"[៧]

១២. នៅក្នុងវិធានច្បាប់ដែលពាក់ព័ន្ធ វិធាន ៦៣(៣) នៃវិធានផ្ទៃក្នុងចែងថា:

ក. សហចៅក្រមស៊ើបអង្កេត អាចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទបានតែក្នុងលក្ខខណ្ឌដូចខាងក្រោម:

[...]

១៣. បទប្បញ្ញត្តិនេះផ្តល់ឆន្ទានុសិទ្ធិឱ្យសហចៅក្រមស៊ើបអង្កេតក្នុងការបង្គាប់ការឃុំខ្លួនបណ្តោះអាសន្ន។ នៅពេលពិចារណាថាតើត្រូវអនុវត្តឆន្ទានុសិទ្ធិនេះ ដែរឬទេ សហចៅក្រមស៊ើបអង្កេតនឹងត្រូវគោរពសិទ្ធ និងបទដ្ឋានជាមូលដ្ឋាន ដែលទទួលស្គាល់ដោយអន្តរជាតិ។

១៤. នៅក្នុងករណីនេះ មាត្រា ៩ ស្តីពីសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សចែងថា:

គ្មានបុគ្គលណា ត្រូវបានគេចាប់ខ្លួន ឃុំខ្លួន ឬនិរទេស តាមទំនើងចិត្តឡើយ។

១៥. មាត្រា ៩(៤) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយចែងថា:

ជនណាដែលត្រូវដកហូតសេរីភាព ដោយការឃាត់ខ្លួន ឬឃុំខ្លួន ត្រូវមានសិទ្ធិដាក់ពាក្យបណ្តឹង ដើម្បីឱ្យតុលាការអាចសម្រេចដោយមិនពន្យារពេល អំពីនីត្យានុកូលភាពនៃការឃុំខ្លួន និងបង្គាប់ឱ្យនៅក្រៅឃុំ បើការឃុំខ្លួននោះមិនស្របច្បាប់។

---

[៧] ដីកាបង្គាប់ការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ C22 វាក្យខណ្ឌទី ៥ និងវាក្យខណ្ឌទី ៦។

១៦. ក្រោយពីពិចារណាសិទ្ធិជាមូលដ្ឋានដែលទទួលស្គាល់ជាអន្តរជាតិនេះរួចមក អង្គបុរេជំនុំជម្រះយល់ឃើញថា ប្រសិនបើយើងអាចមើលឃើញកាលៈទេសៈ ដែលបានផ្តល់ភស្តុតាងយ៉ាងច្បាស់ថា ជាការរារាំងដល់ការកាត់ទោសដោយអង្គជំនុំជម្រះសាលាដំបូង ការចេញដីកាឱ្យនាំខ្លួន ឬដីកាឃុំខ្លួន គឺធ្វើឡើងដោយខុសនឹងច្បាប់។

១៧. ដូច្នេះ សហចៅក្រមស៊ើបអង្កេតបានអនុវត្តកិច្ចរបស់ខ្លួនត្រឹមត្រូវ ក្នុងការពិនិត្យលើបញ្ហាពិសេស (ដូចដែលបានលើកឡើងនៅក្នុងវាក្យខណ្ឌទី ១១ ខាងលើ) នៅក្នុងរឿងក្តីនេះ។ នៅក្នុងការពិនិត្យបណ្តឹងឧទ្ធរណ៍នេះ អង្គបុរេជំនុំជម្រះនឹងអនុវត្តវិធីសាស្ត្រដូចគ្នា។

១៨. យោងតាមកំណត់ហេតុនៃសវនាការតទល់គ្នា ជនត្រូវចោទ និងសហមេធាវីជាតិបានលើកឡើងបញ្ហាលើកលែងទោស ដែលជនត្រូវចោទទួលបាន។[៨] សហចៅក្រមស៊ើបអង្កេតបានពិចារណាបញ្ហានេះ ប៉ុន្តែមិនបានពិចារណាឱ្យបានពេលពេញ និងពិស្តារ ដូចដែលជនត្រូវចោទ និងសហមេធាវីរបស់គាត់ ដែលពួកគេមានលទ្ធភាពពិចារណាបានត្រឹមត្រូវ និងរៀបចំសេចក្តីសន្និដ្ឋាន។ អង្គបុរេជំនុំជម្រះយល់ឃើញថា នៅពេលផ្តល់លទ្ធភាពនេះដល់សហមេធាវីការពារក្តីនៅក្នុងដំណាក់កាលបណ្តឹងឧទ្ធរណ៍ចំពោះ ដីកាបង្គាប់ការឃុំខ្លួនបណ្តោះអាសន្ននេះ ការខកខានធ្វើដូច្នេះត្រូវបានប៉ះប៉ូវនៅពេលនេះ។ អង្គបុរេជំនុំជម្រះនឹងផ្អែកការវិនិច្ឆ័យរបស់ខ្លួន លើសេចក្តីសន្និដ្ឋានពិស្តារនៃបណ្តឹងឧទ្ធរណ៍របស់ភាគីទាំងអស់។

១៩. នៅក្នុងសារណាបណ្តឹងឧទ្ធរណ៍ សហមេធាវីការពារក្តីបានលើកឡើងថា បញ្ហាស្តីពី*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (ne bis in idem)* និងព្រះរាជក្រឹត្យលើកលែងទោសដល់ជនត្រូវចោទ នឹងមិនយកមកលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ឡើយ។ សហមេធាវីការពារក្តីរក្សាសិទ្ធិ ក្នុងការលើករាល់បញ្ហាណាមួយ និងរាល់អញ្ញត្រកម្មទាំងអស់ចំពោះការវិភាគផ្នែកច្បាប់របស់សហចៅក្រមស៊ើបអង្កេត ព្រមទាំងការវិនិច្ឆ័យលើបញ្ហាទាំងនេះ នៅ

---

[៨] នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ អនុលោមតាមវិធាន ៦៣ នៃវិធានផ្ទៃក្នុង សវនាការតទល់គ្នា ត្រូវបានរៀបចំឡើង ដើម្បីឱ្យសហចៅក្រមស៊ើបអង្កេតសម្រេចថាតើគួរឬមិនគួរចេញដីកាបង្គាប់ការឃុំខ្លួនបណ្តោះអាសន្ន។ សូមអាន កំណត់ហេតុនៃសវនាការតទល់គ្នា ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ C19។

00233011



ពេលសមស្របជាងនេះ។ នៅក្នុងការយល់ឃើញរបស់សហមេធាវីការពារក្តី សេចក្តីសម្រេចនេះ នឹងមិនអាចចាត់ទុកថា ជាការបោះបង់សិទ្ធិនេះឡើយ។

២០. នៅក្នុងករណីនេះ អង្គបុរេជំនុំជម្រះសង្កេតឃើញថា សេចក្តីសន្និដ្ឋានដែលលើកឡើងនៅចំពោះមុខអង្គបុរេជំនុំជម្រះនៅក្នុងបណ្តឹងឧទ្ធរណ៍នាពេលបច្ចុប្បន្ន មិនអាចនាំដល់ការបោះបង់សិទ្ធិក្នុងការលើកឡើងអំណះអំណាងទាំងឡាយ នៅក្នុងដំណាក់ការនីតិវិធីលើកក្រោយ អនុលោមតាមបទប្បញ្ញត្តិដូចខាងក្រោម៖

២១. វិធាន ៧៤(៣)(ក) ចែងថា:

> ជនត្រូវចោទអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតដូចខាងក្រោម:
>
> ក. ការបញ្ជាក់ពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ

២២. អនុលោមតាមចំណងជើងនៃ“នីតិវិធីនៅអង្គជំនុំជម្រះសាលាដំបូង” វិធាន ៨៩(១)នៃវិធានផ្ទៃក្នុង នៅក្នុងវិធានច្បាប់ដែលពាក់ព័ន្ធចែងថា:

> ១. អញ្ញត្រកម្មទាក់ទងនឹង:
>
> ក) យុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង
>
> ខ) ការរលត់បណ្តឹងអាជ្ញា
>
> គ) [...]
>
> ត្រូវលើកឡើងនៅក្នុងសវនាការបឋម បើមិនដូចនោះទេ មិនអាចត្រូវបានទទួលយកឡើយ។

២៣. អនុលោមតាមវិធានផ្ទៃក្នុងស្តីពីនីតិវិធីនៅអង្គជំនុំជម្រះសាលាដំបូង អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា បញ្ហាដែលត្រូវបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ អាចលើកឡើងបានទាំងស្រុង នៅក្នុងដំណាក់ការនីតិវិធីលើកក្រោយ ដោយសារតែបញ្ហាទាំងនេះអាចនាំដល់ការរលត់បណ្តឹងអាជ្ញា។ ដូច្នេះ ការដែលមិនលើកអំណះអំណាងទាំងស្រុងនៅចំពោះមុខអង្គបុរេជំនុំជម្រះនៅក្នុងដំណាក់ការនេះ មិនអាចយល់ឃើញថា ជាការបោះបង់សិទ្ធិក្នុងការតវ៉ាឡើយ។



អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER * CHAMBRE PRÉLIMINAIRE * ECCC

## ២. អង្គហេតុ

២៤. នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៧៩ ក្រឹត្យច្បាប់លេខ ១ ត្រូវបានប្រកាសឱ្យប្រើប្រាស់ ដែលនៅក្នុងវិធានច្បាប់ដែលពាក់ព័ន្ធ ក្រឹត្យនេះចែងថា:

"ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា [...] សម្រេចដូចខាងក្រោម:

មាត្រា ១: បង្កើតតុលាការប្រជាជនបដិវត្តនៅទីក្រុងភ្នំពេញ ដើម្បីជំនុំជម្រះអំពើប្រល័យពូជសាសន៍ដែលប្រព្រឹត្តដោយបន ប៉ុល ពត-អៀង សារី សម្លាប់រង្គាលប្រជាជនស្លូតត្រង់ជាច្រើនដោយមានគម្រោងផែនការបណ្តេញប្រជាជនឱ្យចាកចេញផុតពីទីក្រុងភ្នំពេញ ភូមិករ ដើម្បីយកទៅប្រមូលផ្តុំ ហើយបង្ខំឱ្យគេធ្វើការបាក់កម្លាំងក្នុងលក្ខណៈប្រល័យកំទេចទាំងខាងរូបកាយ ទាំងខាងស្មារតីរបស់គេទាំងនោះ កំទេចសាសនា បំផ្លិចបំផ្លាញរចនាសម្ព័ន្ធ វប្បធម៌ និង ទំនាក់ទំនងផ្សេងៗក្នុងគ្រួសារ និងសង្គម។"[៩]

២៥. យោងតាមសាលក្រមរបស់តុលាការប្រជាជនបដិវត្ត ប៉ុលពត និងអៀង សារី ត្រូវបានចោទប្រកាន់តាមរយៈដីកាបញ្ជូនរឿងឱ្យទៅជំនុំជម្រះចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៩។[១០] យោងតាមសាលក្រម តុលាការប្រជាជនបដិវត្តបានបើកសវនាការចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៩ ដើម្បីធ្វើការវិនិច្ឆ័យជនជាប់ចោទ។[១១] នៅក្នុងខែសីហា ឆ្នាំ១៩៧៩ តុលាការប្រជាជនបដិវត្ត បានចេញសាលក្រមរបស់ខ្លួន ដែលមានខ្លឹមសារនៅក្នុងវាក្យខណ្ឌដែលពាក់ព័ន្ធដូចខាងក្រោម:

"យល់ឃើញថាឈ្មោះ ប៉ុល ពត និង អៀង សារី ពិតជាបានប្រព្រឹត្តបទប្រល័យពូជសាសន៍ដែលមានចែងនៅក្នុងក្រឹត្យច្បាប់លេខ ១ ចុះថ្ងៃទី១៥ កក្កដា ១៩៧៩ [...]"[១២]

"យល់ឃើញ ការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់ជនជាប់ចោទនីមួយៗ៖

[...]

អៀង សារី ក្នុងនាទីជាសមាជិកគណៈអចិន្ត្រៃយ៍នៃការិយាល័យនយោបាយ និងជាឧបនាយករដ្ឋមន្ត្រីរបស់រដ្ឋាភិបាលទទួលបន្ទុកកិច្ចការបរទេសដែលជាបន្ទុកខ្ពស់ មានសិទ្ធិអំណាចបរិបូរណ៍ បានរួមជាមួយ ប៉ុល ពត ដឹកនាំរួម ជាអ្នករចនា និងអនុវត្តចំណាងទាក់ទងឃុបឃិតជាមួយ

---

[៩] ក្រឹត្យច្បាប់លេខ ១ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៧៩ ទំព័រទី១

[១០] សាលក្រមរបស់តុលាការប្រជាជនបដិវត្ត UN Doc. A/34/491 ចុះខែសីហា ឆ្នាំ១៩៧៩ ទំព័រទី ២។ សម្រង់នៅក្នុងសាលដីកានេះ ដកស្រង់ចេញពីសាលក្រម ដែលចែងនៅក្នុង ដីកាបង្គាប់ការឃុំខ្លួនបណ្តោះអាសន្ន ។

[១១] សាលក្រមរបស់តុលាការប្រជាជនបដិវត្ត ទំព័រទី ២។

[១២] សាលក្រមរបស់តុលាការប្រជាជនបដិវត្ត ទំព័រទី ២៨។



ECCC CETC PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

បនប្រតិកិរិយាប៉េកាំង និងបនប្រតិកិរិយាអន្តរជាតិផ្សេងទៀត ដែលជាអ្នកចាំជួយដោះសារនូវអំពើប្រល័យពូជសាសន៍របស់ពួកវានៅលើឆាកអន្តរជាតិ។ គឺ អៀង សារី នេះហើយជាអ្នកចេញអាជ្ញាឱ្យហៅបញ្ញវ័ន្ត និស្សិត ដែលកំពុងប្រកបការងាររៀនសូត្រឯប្រទេសក្រៅ ឱ្យចូលមកស្រុកវិញ គឺ អៀង សារី នេះហើយជាអ្នកទទួលខុសត្រូវដោយផ្ទាល់អំពីទោសសម្លាប់បញ្ញវ័ន្ត និស្សិតជាតិឯងដោយបោកបញ្ឆោតយកមកពីបរទេស [...]"[១៣]

"តុលាការប្រជាជនបដិវត្តតាំងនៅទីក្រុងភ្នំពេញ

១. ប្រកាសថាឈ្មោះ ប៉ុល ពត ហៅ សាឡុត ស និង ឈ្មោះ អៀង សារី ពិតជាបានប្រព្រឹត្ត"បទឧក្រិដ្ឋប្រល័យពូជសាសន៍"មែន។

២. ប្រកាសកាត់ទោសប្រហារជីវិតបង់ លើឈ្មោះ ប៉ុល ពត ហៅ សាឡុត ស និងឈ្មោះ អៀង សារី។

៣. ប្រកាសរឹបអូសទ្រព្យសម្បត្តិទាំងអស់ របស់ឈ្មោះ ប៉ុល ពត ហៅ សាឡុត ស និងឈ្មោះ អៀង សារី

[...]"[១៤]

២៦. នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៩៤ សភាជាតិនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងទីក្រុងភ្នំពេញបានអនុម័ត"ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់" ("ច្បាប់ចុះឆ្នាំ១៩៩៤")។ ច្បាប់នេះចែង នៅក្នុងបញ្ញត្តិដែលពាក់ព័ន្ធថា:

រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

[...]

ដោយតាំងពីពេលបោះឆ្នោតឆ្នាំ ១៩៩៣ រៀងរហូតមក មកទល់នឹងបច្ចុប្បន្ន ក្រុមកម្ពុជាប្រជាធិបតេយ្យ បានប្រព្រឹត្តជាបន្តបន្ទាប់នូវ ឧក្រិដ្ឋកម្ម ភេរវកម្ម និងអំពើប្រល័យពូជសាសន៍ ដែលជាចរិតពិតរបស់ក្រុមខ្លួន តាំងពីក្រុមខ្លួន ដណ្តើមយកអំណាច កាន់កាប់នៅ ខែមេសា ឆ្នាំ១៩៧៥ [...]

[...]

ដោយយល់ឃើញថា មេដឹកនាំនៃក្រុម "កម្ពុជាប្រជាធិបតេយ្យ" មិនអាចយកកិច្ចព្រមព្រៀងនាទីក្រុងប៉ារីសស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះនៅកម្ពុជា ធ្វើជាខែលខាងច្បាប់ សំរាប់លាក់បំបាំង យករួចខ្លួនពីការទទួលខុសត្រូវរបស់ពួកខ្លួន ដែលបានប្រព្រឹត្ត ឧក្រិដ្ឋកម្ម ភេរវកម្ម និងអំពើប្រល័យពូជសាសន៍ ចាប់តាំងពីពេលរបប ប៉ុល ពត ដណ្តើមអំណាចនៅឆ្នាំ ១៩៧៥ - ១៩៧៨។ បទឧក្រិដ្ឋប្រល័យពូជសាសន៍ គ្មានអាជ្ញាយុកាលឡើយ។

[១៣] សាលក្រមរបស់តុលាការប្រជាជនបដិវត្ត ទំព័រទី ២៩។

[១៤] សាលក្រមរបស់តុលាការប្រជាជនបដិវត្ត ទំព័រទី ២៩។

[...] អនុម័ត ច្បាប់ដែលមានបញ្ញត្តិដូចតទៅ ៖

មាត្រា ៣ - សមាជិក អង្គការនយោបាយ និង កំលាំងយោធារបស់ក្រុម"កម្ពុជាប្រជាធិបតេយ្យ" ឬ ជនណា ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ធ្វើមនុស្សឃាត ដោយចេតនា ចាប់បង្ខំនារី សេពសន្ថវៈ ប្លន់ទ្រព្យសម្បត្តិរបស់ប្រជារាស្ត្រ បំផ្លិចបំផ្លាញ ទ្រព្យសម្បត្តិសាធារណៈ និងឯកជន។ល។ ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។

មាត្រា ៤ - សមាជិក អង្គការនយោបាយ និង កំលាំងយោធារបស់ក្រុម"កម្ពុជាប្រជាធិបតេយ្យ" ឬ ជនណា ដែលបានប្រព្រឹត្ត៖

- ធ្វើសកម្មភាព អបគមន៍
- បំផ្លាញ រាជរដ្ឋាភិបាល
- បំផ្លាញ អង្គការនៃអំណាចសាធារណៈ
- ញុះញង់ ឬ បង្ខំពលរដ្ឋ អោយកាន់អាវុធ ប្រឆាំងនឹងអាជ្ញាធរសាធារណៈ

ត្រូវចាត់ទុកជាជនឧក្រិដ្ឋប្រឆាំងនឹងសន្តិសុខ ក្នុងប្រទេស ហើយត្រូវផ្តន្ទាទោសដាក់គុកពី២០ ឆ្នាំ ទៅ ៣០ឆ្នាំ ឬអស់មួយជីវិត។

មាត្រា ៥ - ច្បាប់នេះអនុគ្រោះទុកពេល ៦ ខែ ក្រោយពីចូលជាធរមាន អោយជនជាសមាជិកអង្គការនយោបាយ ឬ ជាកំលាំងយោធានៃក្រុម "កម្ពុជាប្រជាធិបតេយ្យ" វិលត្រលប់មករួមរស់ក្រោមការគ្រប់គ្រង របស់រាជរដ្ឋាភិបាលក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនយកទោសពៃរ៍ចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។

មារតា ៦ - ចំពោះមេដឹកនាំនៃក្រុម "កម្ពុជាប្រជាធិបតេយ្យ" មិនអាចមានការអនុគ្រោះ ដូចមានចែងក្នុងច្បាប់នេះឡើយ ។

មាត្រា ៧ - ព្រះមហាក្សត្រទ្រង់ អាចបន្ធូរបន្ថយទោស ឬលើកលែងទោស តាមព្រះរាជសិទ្ធិ ដែលមានចែងក្នុងមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញ។

[...]

មាត្រា ៩ - ជនណាមួយដែលយកច្បាប់នេះ ទៅរំលោភសិទ្ធិរបស់ប្រជាពលរដ្ឋ ដោយធ្វើការគម្រាមកំហែង ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន ការធ្វើទារុណកម្ម ឬរំលោភលើលំនៅដ្ឋានមិនត្រឹមត្រូវ ត្រូវផ្តន្ទាទោស ដាក់គោកពី ពីរ ឆ្នាំ ទៅ ប្រាំ ឆ្នាំ។

អ្នកផ្តល់ព័ត៌មានមិនពិត អ្នកធ្វើសក្សីភូតកុហក អ្នកក្លែងបង្កើតភស្តុតាង ដើម្បីបម្រើផលប្រយោជន៍ នៃការយកច្បាប់នេះ ទៅរំលោភសិទ្ធិប្រជាពលរដ្ឋ ត្រូវផ្តន្ទាទោស ដាក់គោកពី ពីរឆ្នាំ ទៅ ប្រាំឆ្នាំ។

ប្រជាពលរដ្ឋ រងគ្រោះ ដោយអយុត្តិធម៌ មានសិទ្ធិប្តឹងតវ៉ា ទាសំណងដើម្បីជួសជុល ការខូតខាត ដែលបង្កើតឡើងពីការរំលោភសិទ្ធិខាងលើ។[១៥]

[១៥] ច្បាប់ស្តីពីការដាក់"ក្រុមកម្ពុជាប្រជាធិបតេយ្យ"ឱ្យនៅក្រៅច្បាប់ ព្រះរាជក្រមលេខ ១/នស៩៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤។





E.C.C.C. C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

២៧. នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៨៦ ព្រះរាជក្រឹត្យលេខ នស/រកត/0៩៨៦/៧២ ត្រូវបានប្រកាសឱ្យប្រើប្រាស់ ដែលព្រះរាជក្រឹត្យនេះចែងថា[១៦]

> យើង ព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី
>
> [...]
>
> ត្រាស់បង្គាប់
>
> **មាត្រា ១**: ត្រូវបានលើកលែងទោសឱ្យលោក អៀង សារី អតីតឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការបរទេសក្នុងរដ្ឋាភិបាលនៃប្រទេសកម្ពុជាប្រជាធិបតេយ្យដែលត្រូវបានផ្តន្ទាទោស ប្រហារជីវិតបង់ និង រឹបអូស ទ្រព្យសម្បត្តិទាំងអស់ តាមអំណាចសាលក្រមរបស់តុលាការប្រជាជនបដិវត្តក្រុងភ្នំពេញ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៩ និង ចំពោះទោសដែលបានកំណត់ដោយច្បាប់ស្តីពី ការដាក់ក្រុមកម្ពុជាប្រជាធិបតេយឱ្យនៅក្រៅច្បាប់ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ 0១ នស ៩៤ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៤។
>
> **មាត្រា ២**: ព្រះរាជក្រឹត្យនេះ មានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ។
>
> **មាត្រា ៣**: ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃនិង ក្រសួងយុត្តិធម៌ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសម្រេចជាស្ថាពរ។[១៧]

២៨. នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២00៣ កិច្ចព្រមព្រៀងត្រូវបានចុះហត្ថលេខារវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីកាត់សេចក្តីក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង")។ កិច្ចព្រមព្រៀងនេះមានចែងនៅក្នុងមាត្រា ១១(២):

> "ប្រការនេះផ្អែកលើសេចក្តីប្រកាសដោយរាជរដ្ឋាភិបាលកម្ពុជាថា រហូតមកដល់ពេលនេះ មានតែករណីមួយគត់ទាក់ទងនឹងបញ្ហាដែលគ្របដណ្តប់ដោយច្បាប់នេះ នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៨៦ ពេលដែលការលើកលែង ទោសត្រូវបានផ្តល់ដល់មនុស្សម្នាក់គត់ដែលត្រូវបានផ្តន្ទាទោសនៅឆ្នាំ១៩៧៩ ពីបទប្រល័យពូជសាសន៍។ អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាឯកភាពគ្នាថា វិសាលភាពនៃការលើកលែងទោសនេះគឺត្រូវសម្រេចដោយ អង្គជំនុំជម្រះវិសាមញ្ញ។"[១៨]

---

[១៦] ព្រះរាជក្រឹត្យជាភាសាខ្មែរ ត្រូវបានបកប្រែទៅជាភាសាអង់គ្លេស ដោយមន្ត្រីបកប្រែរបស់តុលាការ។ ដូច្នេះ ព្រះរាជក្រឹត្យនេះខុសពីព្រះរាជក្រឹតជាភាសាអង់គ្លេសនៅក្នុងសំណុំរឿង។

[១៧] ព្រះរាជក្រឹត្យលេខ នស/រកត/0៩៨៦/៧២ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៨៦។

[១៨] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២00៣ មាត្រា ១១(២)។

00233016

E22 / F / 74



២៩. នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទាក់ទងនឹងការកាត់សេចក្តី នូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់អ.វ.ត.ក") ត្រូវបានប្រកាសឱ្យប្រើប្រាស់ ដែលច្បាប់នេះមានចែងនៅក្នុងមាត្រា ៤០ ថ្មី ថា:

> "[...] វិសាលភាពនៃការលើកលែងទោស ឬការអនុគ្រោះទោស ដែលត្រូវបានផ្តល់ឱ្យមុនការអនុម័តច្បាប់នេះ គឺត្រូវសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ។"[១៩]

៣០. យោងតាមរបាយការណ៍នៃការចាប់ខ្លួនលោក អៀង សារី និងលោកស្រី អៀង ធីរិទ្ធ និងការឆែកឆេរផ្ទះ នៅក្នុងទីក្រុងភ្នំពេញ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧:

> នៅម៉ោង ៦:០៥ នាទីព្រឹក មន្ត្រីយុត្តិធម៌ដែលបានកំណត់ឈ្មោះ ដោយមានការគាំទ្រពីកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងមន្ត្រីនគរបាលមូលដ្ឋាន បានអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន អនុលោមតាមលក្ខខណ្ឌនៃដីកានោះ ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០០៧ [...] និងបានចាប់ខ្លួនលោក អៀង សារី និងលោកស្រី អៀង ធីរិទ្ធ។[២០]

៣១. នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេត បានចេញដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន ដោយធ្វើការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នរយៈពេលមិនឱ្យលើសពីមួយ (១) ឆ្នាំ។[២១]

## ៣. សេចក្តីសន្និដ្ឋានរបស់ភាគី

### ក. គោលការណ៍*គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ (ne bis in idem)*

៣២. សហមេធាវីការពារក្តីសន្និដ្ឋានថា អនុលោមតាមគោលការណ៍*គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ (ne bis in idem)* ការជំនុំជម្រះ និងការកាត់ទោសជនត្រូវចោទ

[១៩] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីចោទប្រកាន់ឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ មាត្រា ៤០(ថ្មី)។

[២០] របាយការណ៍ស្តីពីការនាំខ្លួនលោក អៀង សារី និង លោកស្រី អៀង ធិរិទ្ធ និងការឆែកឆេរផ្ទះរបស់គាត់ ដែលមានអាសយដ្ឋានក្នុងក្រុងភ្នំពេញ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧ ទំព័រទី ១។

[២១] ដីកាបង្គាប់ឱ្យឃុំខ្លួន ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C. * C.E.T.C.

ដោយតុលាការប្រជាជនបដិវត្ត នៅក្នុងឆ្នាំ១៩៧៩ រារាំងការចោទប្រកាន់លើជនត្រូវចោទនៅចំពោះមុខអ.វ.ត.ក។

៣៣. សហមេធាវីការពារក្តីអះអាងថា គោលការណ៍*គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ (ne bis in idem)* ជាការរារាំងចំពោះការចោទប្រកាន់ នៅពេលដែលបុគ្គលណាមួយត្រូវបានកាត់ទោសដោយផ្អែកលើអំពើតែមួយ ហើយគោលការណ៍នេះ អនុវត្តចំពោះជនត្រូវចោទ ដោយសារមូលដ្ឋាននៃអង្គហេតុនៅក្នុងឆ្នាំ១៩៧៩ គ្របដណ្តប់បទឧក្រិដ្ឋកម្មទាំងអស់ ដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ សហមេធាវីការពារក្តីបានយកមាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៧ (“ក.ន.ព.ក”) មកគាំទ្រចំពោះការយល់ឃើញរបស់ខ្លួន។

៣៤. សហព្រះរាជអាជ្ញាសន្និដ្ឋានថា មូលហេតុនៃគោលការណ៍*គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ (ne bis in idem)* មានបំណងការពារបុគ្គលណាមួយ ដែលទទួលការឈឺចាប់លំបាកវេទនាពីការជំនុំជម្រះ ឬការទទួលទោស ចំនួនពីរដង។ យោងតាមសហព្រះរាជអាជ្ញា ករណីនេះមិនអនុវត្តចំពោះរឿងក្តីរបស់ជនត្រូវចោទឡើយ ដោយសារគាត់មិនបានទទួលរងការឈឺចាប់លំបាកវេទនា ឬការទទួលទោសដែលគួរឱ្យកត់សម្គាល់ ពីដំណើរការក្តីក្នុងឆ្នាំ១៩៧៩។ សហព្រះរាជអាជ្ញាសន្និដ្ឋានបន្ថែមទៀតថា គោលការណ៍*គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ (ne bis in idem)* តម្រូវឱ្យការជំនុំជម្រះលើកទីមួយធ្វើឡើងដោយឯករាជ្យ និងមិនលម្អៀង អនុលោមតាមបទដ្ឋាន និងនិយាមត្រឹមត្រូវតាមផ្លូវច្បាប់ ដែលទទួលស្គាល់ដោយអន្តរជាតិ។ ដោយសារនីតិវិធីក្នុងឆ្នាំ១៩៧៩ មិនបានអនុវត្តស្របតាមបទដ្ឋានជំនុំជម្រះដោយយុត្តិធម៌ ដែលទទួលស្គាល់ដោយអន្តរជាតិ គោលការណ៍ *គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ (ne bis in idem)* នេះ មិនអនុវត្តឡើយចំពោះករណីនេះ។

៣៥. ជាជម្រើសផ្សេងមួយផ្សេងវិញ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការអនុវត្តន៍ និងយុត្តិសាស្ត្រអន្តរជាតិចំពោះការចោទប្រកាន់ត្រួតគ្នា មិនបានធ្វើឱ្យប៉ះពាល់ដល់គោលការណ៍*គ្មានការកាត់*





PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

*ទោសពីរដង ចំពោះបទល្មើសតែមួយ (ne bis in idem)* ឡើយ។ អនុលោមតាមការអនុវត្តន៍នេះ ការចោទប្រកាន់ត្រួតគ្នា និងការកាត់ទោសច្រើនដងជាបន្តបន្ទាប់នៅក្នុងរឿងក្តីតែមួយ ដែលកើតចេញពីការប្រព្រឹត្តតែមួយ ត្រូវបានអនុញ្ញាត ដរាបណាបទល្មើសបន្ថែមទាំងនោះមានលក្ខខណ្ឌតម្រូវផ្នែកច្បាប់ពិសេស ដែលបទល្មើសដទៃគ្មាន និងនៅពេលដែលបទល្មើសបន្ថែមទាំងនេះ ផ្តល់ផលប្រយោជន៍នយោបាយខុសគ្នា។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ភាពអយុត្តិធម៌ណាមួយដែលកើតចេញពីការកាត់ទោសច្រើនដង អាចលើកឡើងនៅពេលសម្រេចផ្តន្ទាទោស។

៣៦. សហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី គាំទ្រការយល់ឃើញរបស់សហព្រះរាជអាជ្ញា។ ពួកគេកត់សម្គាល់ឃើញថា មាត្រា ១២ នៃ ក.ន.ព.ក ចែងអំពី គោលការណ៍*គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ (ne bis in idem)* ប៉ុន្តែ មាត្រានេះមិនបានចែងអំពីថាតើករណីអ្វីទៅដែលធ្វើឱ្យសាលក្រមមានសុពលភាពត្រឹមត្រូវ។ ដោយសារភាពចន្លោះប្រហោងនៅក្នុងច្បាប់កម្ពុជា សហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីតវ៉ាថា មាត្រា ៣៣ នៃច្បាប់ អ.វ.ត.ក នៅជាធរមាន ដែលមាត្រានេះចែងថា នៅពេលច្បាប់កម្ពុជា មិនមានចែង ឬផ្ទុយពីបទដ្ឋានអន្តរជាតិ ច្បាប់អន្តរជាតិនៅជាធរមាន។ ដូច្នេះ ច្បាប់អន្តរជាតិ អាចយកមកអនុវត្តដើម្បីសម្រេចនៅពេលដែលសាលក្រមមួយមានសុពលភាពត្រឹមត្រូវ។ សហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថា ដោយសារការជំនុំជម្រះនៅចំពោះមុខតុលាការប្រជាជនបដិវត្តបង្កឱ្យមានការរំលោភសិទ្ធិរបស់ជនត្រូវចោទយ៉ាងធ្ងន់ធ្ងរ ជនត្រូវចោទមិនអាចចង្អុលយោងលើការកាត់ទោសនៅក្នុងឆ្នាំ១៩៧៩ ហើយមិនអាចយក គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (ne bis in idem)* មកធ្វើជាមូលដ្ឋានបានទេ។

## ខ. ព្រះរាជក្រឹត្យ

៣៧. សហមេធាវីការពារក្តីសន្និដ្ឋានថា ច្បាប់ឆ្នាំ១៩៩៤ បានគ្របដណ្តប់លើអំពើ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ហើយព្រះរាជក្រឹត្យអនុវត្តចំពោះអំពើទាំងអស់នោះ។ សហមេធាវីការពារក្តីអះអាងថា បុព្វកថានៃច្បាប់ឆ្នាំ១៩៩៤ ចែងយ៉ាងច្បាស់ថា ច្បាប់នេះគ្របដណ្តប់ចំពោះអំពើទាំងអស់





PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

និងបទល្មើស ដែលត្រូវបាន អ.វ.ត.ក រួមបញ្ចូល ឬដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក។ ដូច្នេះ អ.វ.ត.ក មិនមានយុត្តាធិការលើជនត្រូវចោទចំពោះបទល្មើសទាំងនេះ។

៣៨. សហព្រះរាជអាជ្ញាសន្និដ្ឋានថា ជនត្រូវចោទទទួលបានការលើកលែងទោសពីការចោទប្រកាន់ជាពិសេសចំពោះ ច្បាប់ឆ្នាំ១៩៩៤ ហើយ បញ្ហាចោទនោះ គឺវិសាលភាពនៃបទល្មើស ក្រោមច្បាប់ឆ្នាំ១៩៩៤ នេះ។ យោងតាមសហព្រះរាជអាជ្ញា បទល្មើសដែលអាចធ្វើការចោទប្រកាន់បាននោះ គឺមានចែងនៅក្នុងមាត្រា ៤ និង ៩ នៃច្បាប់នេះ។

៣៩. ជាជម្រើសមួយផ្សេងទៀត សហព្រះរាជអាជ្ញាសន្និដ្ឋានថា ទោះបីព្រះរាជក្រឹត្យមានគោលបំណងរារាំងការចោទប្រកាន់នៅពេលអនាគតក៏ដោយ ច្បាប់អន្តរជាតិមិនអនុញ្ញាតឱ្យមានការលើកលែងទោសបែបនេះទេ ដោយសារបទប្រល័យពូជសាសន៍គឺត្រូវបានគេចាត់ទុកថា ជាបទល្មើសដែលមាននិយាមខ្ពស់ហើយមិនអាចរំលោភបំពានបាន (Jus Cogen crime)។

៤០. សហមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីសន្និដ្ឋានថា ព្រះរាជក្រឹត្យគ្មានសុពលភាពឡើយ ដោយសារ អនុលោមតាមច្បាប់កម្ពុជា ការលើកលែងទោសអាចអនុវត្តទៅបាន នៅពេលដែលមានការអនុវត្តន៍ទោសមួយភាគពីរ តែប៉ុណ្ណោះ។ ម៉្យាងវិញទៀត ព្រះរាជក្រឹត្យអាចមានអានុភាព ក្នុងករណីដែលការដាក់ទោសនៅក្នុងឆ្នាំ១៩៧៩ មានសុពលភាពត្រឹមត្រូវ។ ដូចដែលបានលើកឡើងខាងលើ សហមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីសន្និដ្ឋានថា ព្រះរាជក្រឹត្យនេះមិនមានអានុភាពឡើយ។

## ៤. សេចក្ដីពិចារណា

### ក. គោលការណ៍*គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ* (ne bis in idem)

៤១. គោលការណ៍*គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ (ne bis in idem)* ចែងថាតុលាការមិនអាចផ្ដួចផ្ដើមនីតិវិធីចោទប្រកាន់បុគ្គលណាមួយ ចំពោះឧក្រិដ្ឋកម្មដែលជាកម្មវត្ថុនៃដំណើរការក្ដីព្រហ្មទណ្ឌម្ដងរួចមកហើយ និងចំពោះឧក្រិដ្ឋកម្មដែលតុលាការបានយកមក

កាត់ទោស ឬ កាត់ឱ្យរួចទោសរួចហើយ។ គោលការណ៍*គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ (ne bis in idem)* ដែលមានប្រភពមកពីប្រព័ន្ធច្បាប់ស៊ីវិលឡូ គឺស្រដៀងនឹងគោការណ៍ គោលការណ៍*ការកាត់ក្តីពីរដង (Double Jeopardy)* ដែលត្រូវបានគេប្រើប្រាស់ជាញឹកញាប់នៅក្នុងប្រព័ន្ធច្បាប់ខំមិនឡូ។ គោលការណ៍ *គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ (ne bis in idem)* ត្រូវបានគេបកស្រាយថា ជនជាប់ចោទ "មិនត្រូវបានគេយកមកកាត់ទោសពីរដង ចំពោះបទចោទតែមួយ។"[២២]

៤២. វិធានផ្ទៃក្នុងនៃអ.វ.ត.ក មិនមានបទប្បញ្ញត្តិចែងដោយផ្ទាល់ ចំពោះគោលការណ៍*គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ (ne bis in idem)*។

៤៣. ភាគីមិនយល់ស្របនឹងករណីថាតើ យើងគួរស្វែងរកបទដ្ឋានណែនាំនៅក្នុងច្បាប់ជាតិ តែប៉ុណ្ណោះ ឬក៏នៅក្នុងច្បាប់អន្តរជាតិផងដែរ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា គោលការណ៍នេះ ចែងផ្សេងៗគ្នានៅក្នុងបទប្បញ្ញត្តិនៃច្បាប់កម្ពុជា និងនៅក្នុងច្បាប់អន្តរជាតិ ហើយគោលការណ៍នេះបានឆ្លុះបញ្ចាំងនៅក្នុងការពិចារណាថាតើអ្វីទៅដែលបង្កើតជា "បទល្មើសតែមួយ"។ អនុលោមតាមច្បាប់កម្ពុជា "បទល្មើសតែមួយ" ចែងថាជា "អង្គហេតុតែមួយ"។[២៣] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ហាមឃាត់ការជំនុំជម្រះលើកក្រោយចំពោះ "បទល្មើសតែមួយ"។

៤៤. មាត្រា ៧ នៃ ក.ន.ព.ក ចែងដូចខាងក្រោម:

"**ការរលត់នៃបណ្តឹងអាជ្ញា**

មូលហេតុនៃការរលត់បណ្តឹងអាជ្ញាមានដូចតទៅគឺ:

១. មរណភាពនៃជនល្មើស។

២. ការផុតអាជ្ញាយុកាល។

---

[២២] រដ្ឋអាជ្ញា ទល់នឹង Tadic សាលដីកាលេខ IT-94-1 ICTY អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ ផ្នែក X ចៅក្រម Nieto Navia។

[២៣] បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌជាភាសាអង់គ្លេស ដែលមានចែង ហើយត្រូវបានអង្គបុរេជំនុំជម្រះចង្អុលយោងនេះ ដកស្រង់ចេញពី "ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បកប្រែភាសាខ្មែរ-អង់គ្លេស បោះពុម្ពលើកទី១ ខែកញ្ញា ឆ្នាំ២00៨"។

00233021

E22/I/74



៣. ការលើកលែងទោសជាទូទៅ។

៤. និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ។

៥. អាជ្ញាអស់ជំនុំ។"

កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទៀតទេ ឬត្រូវតែបញ្ឈប់។

៤៥. មាត្រា ១២ នៃ ក.ន.ព.ក ចែងថា:

**អាជ្ញាអស់ជំនុំ**

ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះបទល្មើសដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ។

៤៦. មាត្រា ១៤(៧)នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ចែងថា:

គ្មានជនណាម្នាក់ ត្រូវយកមកចោទប្រកាន់ ឬយកមកផ្តន្ទាទោសសារជាថ្មីឡើយ ចំពោះបទល្មើស ដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋ នីមួយៗរួចហើយ។

៤៧. គោលការណ៍*គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ (ne bis in idem)* មានការជាប់ពាក់ព័ន្ធនឹងទ្រឹស្តីអាជ្ញាអស់ជំនុំ ក្នុងលក្ខណៈចង្អៀត ដោយសារផលវិបាកនៃទ្រឹស្តី *អាជ្ញាអស់ជំនុំ* គឺថា គ្មានបុគ្គលណាមួយ ត្រូវបានយកមកកាត់ទោសម្តងទៀត ចំពោះបទចោទដដែល បន្ទាប់ពីសាលក្រមចូលជាស្ថាពរ។ ដូចដែលបានរៀបរាប់នៅខាងលើក្នុងវាក្យខណ្ឌទី ៤៥, មាត្រា ១២ នៃ ក.ន.ព.ក អាចយកមកធ្វើជាគម្រូចំពោះការអនុវត្តន៍ទ្រឹស្តី *អាជ្ញាអស់ជំនុំ*។

៤៨. នៅក្នុងចំនុចខាងក្រោម អង្គបុរេជំនុំជម្រះនឹងធ្វើការពិចារណាថាតើ ការជំនុំជម្រះ និងការកាត់ទោសក្នុងឆ្នាំ១៩៧៩ បង្ហាញជាភស្តុតាងជាក់លាក់ថា នឹងរារាំងដល់ការកាត់ទោសលើកនេះដែរឬទេ នៅពេលធ្វើការអនុវត្តការបកស្រាយផ្សេងលើគោលការណ៍នេះ។

00233022

C22/D174



៤៩. ក្រឹត្យច្បាប់លេខ ១ និងក្រឹត្យច្បាប់លេខ ២ រួមទាំងសាលក្រមរបស់តុលាការប្រជាជនបដិវត្ត បង្ហាញថា ជនត្រូវចោទបានកាត់ទោសម្តងរួចមកហើយ ហើយត្រូវបានដាក់ឱ្យជាប់ទោសពីបទ"ប្រល័យពូជសាសន៍"។

៥០. នៅក្នុងដំណាក់ការនេះ ជនត្រូវចោទកំពុងដាក់ឱ្យស្ថិតនៅក្រោមការចោទប្រកាន់ យោងតាមកំណត់នៃការចូលខ្លួនដំបូង ដែលមានចែងដូចខាងក្រោមៈ

បន្ទាប់ពីបានកត់ត្រានូវអត្តសញ្ញាណរបស់ជននេះរួចហើយ យើងបានប្រាប់ដល់ជននេះអំពីអង្គហេតុនីមួយៗ ដែលបានប្តឹងមកយើងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់លោក-លោកស្រីសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញលេខ ០០៨ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧។ យើង បានប្រាប់ដល់ជននេះថា អង្គហេតុដែលបានលើកឡើងដោយលោក-លោកស្រីសហព្រះរាជអាជ្ញានៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ហើយដែលត្រូវរៀបរាប់ឡើងវិញដូចខាងក្រោមនេះ អាចកំណត់ជាបទល្មើសដូចខាងក្រោមៈ

- **ការរំលោភបំពានក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦** (មនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញដល់ពុទ្ធិសាសនិក និង សាសនិកឥស្លាម)
- **បទប្រល័យពូជសាសន៍** (លើពុទ្ធិសាសនិក ជនជាតិចាម និងវៀតណាម)
- **បទប្រឆាំងនឹងមនុស្សជាតិ** (មនុស្សឃាត ការសម្លាប់បំផុតពូជ ការដាក់ជាទាសករ ការនិរទេស ការដាក់ឃុំឃាំង ការធ្វើទារុណកម្ម ការចាប់រំលោភ ការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ ជាតិសាសន៍ និងសាសនា លើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ សមាជិកនៃវណ្ណៈសក្តិភូមិ មូលធន និងគហបតី "ប្រជាជនថ្មី" ជនដែលគេសន្មតជាមុនថាជា "ធាតុមិនល្អ" ពុទ្ធិសាសនិក ជនជាតិចាម និង វៀតណាម និងអំពើអមនុស្សធម៌ដទៃទៀត)
- **ការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩** (ការសម្លាប់ដោយចេតនា ការធ្វើទារុណកម្ម ឬការប្រព្រឹត្តអមនុស្សធម៌ ការបង្កឲ្យសនកម្មធ្ងន់ធ្ងរ ឬការធ្វើឱ្យឈឺចាប់ខ្លាំងដោយចេតនាដល់រាងកាយ ឬសុខភាព និង ការធ្វើឱ្យខូចខាតធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិ ដោយគ្មានហេតុផលចាំបាច់ខាងផ្នែកយោធា ដែលត្រូវបានអនុវត្តដោយខុសច្បាប់ និង ដោយគ្មានត្រាប្រណី ការដកហូតពីអ្នកទោសសង្គ្រាម ឬជនស៊ីវិល នូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងទៀងទាត់ និង ការនិរទេស ឬផ្ទេរសដោយបង្ខំ ឬការបង្ខាំងជនស៊ីវិលដោយខុសច្បាប់)។

ចំពោះអង្គហេតុដែលយើងបានបញ្ជាក់ខាងលើ យើង ប្រាប់ដល់ជននេះថាយើងដាក់ជននេះឱ្យស្ថិតនៅក្រោមការពិនិត្យនូវអង្គហេតុដែលយើងបញ្ជាក់អំពីបទល្មើសដូចខាងក្រោមៈ



PRE-TRIAL CHAMBER · CHAMBRE PRÉLIMINAIRE · ECCC · CETC

- **បទល្មើសប្រឆាំងនឹងមនុស្សជាតិ** (មនុស្សឃាត ការដាក់ឃុំឃាំង ការធ្វើទុក្ខបុកម្នេញ ការសម្លាប់បំផុតពូជ និងអំពើអមនុស្សធម៌ដទៃទៀត) និង
- **ការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩** (ការសម្លាប់ដោយចេតនា ការបង្កព្យសនកម្មធ្ងន់ធ្ងរ ឬការធ្វើឱ្យឈឺចាប់ខ្លាំងដោយចេតនាដល់រាងកាយ និងសុខភាព ការដកហូតដោយចេតនាពីអ្នកទោសសង្គ្រាម ឬជនស៊ីវិល នូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ការឃុំឃាំងដោយខុសច្បាប់ ការនិរទេស ឬជម្លៀស ដោយខុសច្បាប់)

បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៥ មាត្រា មាត្រា ២៩ (ថ្មី) និង មាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

ចំពោះការដែលជននេះបានប្រព្រឹត្តនៅលើទឹកដីនៃប្រទេសកម្ពុជារវាងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និង ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩:

- ក្នុងឋានៈជារដ្ឋមន្ត្រីក្រសួងកិច្ចការបរទេស ដែលនៅក្នុងនោះជននេះបានប្រើប្រាស់អំណាចនិងការកាន់កាប់យ៉ាងពេញលេញទៅលើក្រសួងនិងអង្គភាពដែលស្ថិតនៅក្រោមចំណុះ និង ក្នុងឋានៈជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិមនិងអចិន្ត្រៃយ៍បក្សកម្មុយនីស្តកម្ពុជា។
- បានញុះញង់ បានបញ្ជា ឧកខានក្នុងការទប់ស្កាត់ ឧកខានក្នុងការដាក់ពិន័យ ឬទណ្ឌកម្ម ឬសម្របសម្រួល និងផ្តល់ជំនួយ ក្នុងការប្រព្រឹត្តនូវបទល្មើសទាំងឡាយខាងលើ។
- ដោយដឹកនាំ លើកទឹកចិត្ត ដាក់ឱ្យអនុវត្ត ឬដោយផ្តល់ជំនួយការក្រោមរូបភាពផ្សេងៗដទៃទៀតដល់គោលនយោបាយ និងការអនុវត្តរបស់បក្សកម្ពុជាប្រជាធិបតេយ្យ ដែលមានលក្ខណៈជាការធ្វើមនុស្សឃាត ការសម្លាប់បំផុតពូជ ការចាប់ដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុកបុកម្នេញដោយហេតុផលនយោបាយ ឬអំពើអមនុស្សធម៌ដទៃទៀត ដូចជា ការជម្លៀសប្រជាជនដោយបង្ខំ ការដាក់ជាទាសករ ឬការដាក់ឱ្យធ្វើការងារដោយបង្ខំ។
- នៅក្នុងក្របខណ្ឌនៃការវាយប្រហារជាប្រព័ន្ធនិងជាទូទៅ សំដៅលើប្រជាជនស៊ីវិល។
- ដោយបញ្ជាក់ថា ក្នុងអំឡុងពេលទាំងអស់ ឬមួយផ្នែកនៃរវាងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ កម្ពុជាប្រជាធិបតេយ្យ និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម ស្ថិតនៅក្នុងស្ថានភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិជាមួយគ្នា។[២៤]

---

[២៤] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការចូលខ្លួនដំបូង ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ D38 ទំព័រទី២ និង ទំព័រទី៣។



PRE-TRIAL CHAMBER * E.C.C.C. * C.E.T.C. * CHAMBRE PRÉLIMINAIRE

៥១. ដោយសារជនត្រូវចោទមិនត្រូវបានចោទប្រកាន់ជាក់លាក់លើបទប្រល័យពូជសាសន៍ អង្គបុរេជំនុំជម្រះយល់ឃើញថា ការចោទប្រកាន់នាពេលនេះ អាចជាការចោទប្រកាន់ "បទល្មើស" ផ្សេង។

៥២. អង្គបុរេជំនុំជម្រះយល់ឃើញថា បទចោទដែលបានកំណត់ដោយសហចៅក្រមស៊ើបអង្កេត ទោះបីគ្រប់គ្រាន់ក្នុងការប្រាប់ដល់ជនត្រូវចោទអំពីបទចោទ ដែលដាក់បន្ទុកលើខ្លួនក៏ដោយ ក៏បទចោទទាំងនេះមានលក្ខណៈស្រពិចស្រពិលមិនអាចឱ្យពិចារណាត្រឹមត្រូវថាតើ ការចោទប្រកាន់នាពេលនេះ គឺផ្អែកលើ"អំពើ"ដដែល ដូចនឹង"អំពើ"ទាំងឡាយ ដែលបានយកមកធ្វើជាសម្អាងនៃបទចោទនៅក្នុងឆ្នាំ១៩៧៩ ឬយ៉ាងណា។ វាជាការមិនអាចធ្វើទៅបាន ឬមិនត្រឹមត្រូវឡើយ ក្នុងការបញ្ជាក់អំពី"អំពើ"ទាំងនេះ នៅពេលសហចៅក្រមស៊ើបអង្កេតចាប់ផ្តើមការស៊ើបអង្កេត។ ក្នុងករណីមានការចេញដីកាបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ នៅពេលនោះសហចៅក្រមស៊ើបអង្កេតនឹងថែង "អង្គហេតុផ្នែកសម្ភារៈ និងបទចោទ" គឺពេលដែលចេញដីកាដំណោះស្រាយ បន្ទាប់ពីសហចៅក្រមស៊ើបអង្កេតបិទការស៊ើបអង្កេត។[២៥]

៥៣. ដូច្នេះ នៅពេលអនុវត្តគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (Ne bis in idem)* ក្នុងវិធីស្មើឡើងផ្សេងៗគ្នា អង្គបុរេជំនុំជម្រះយល់ឃើញថា នៅក្នុងដំណាក់កាលនេះ វាមិនបង្ហាញជាភស្តុតាងច្បាស់លាស់ថា ការជំនុំជម្រះក្នុងឆ្នាំ១៩៧៩ និងការកាត់ឱ្យជាប់ទោសនោះ នឹងអាចរារាំងការកាត់ទោសម្តងទៀតដោយ អ.វ.ត.កឡើយ។ ចំនុចនេះនឹងបង្ហាញចេញច្បាស់ នៅពេលចេញដីកាបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ដែលនៅដំណាក់ការនោះ បទចោទជាក់លាក់ និងអង្គហេតុផ្នែកសម្ភារៈដែលយកមកធ្វើជាសម្អាង នឹងដាក់ចេញឱ្យឃើញយ៉ាងច្បាស់។

៥៤. នៅពេលពិនិត្យការវិនិច្ឆ័យនេះ អង្គបុរេជំនុំជម្រះនឹងមិនធ្វើការពិចារណាអំពីបញ្ហាថាតើ ការជំនុំជម្រះក្នុងឆ្នាំ១៩៧៩ បានបំពេញបំពេញបទដ្ឋានតម្រូវអប្បបរមារដែរឬទេ ដើម្បីអាចឱ្យ

---

[២៥] សូមអាន វិធាន ៦៧ នៃវិធានផ្ទៃក្នុង។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* (*Ne bis in idem*) យកមកអនុវត្តបាន។

## ខ. ព្រះរាជក្រឹត្យ

៥៥. អនុលោមតាម ព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៦/៧២ និង"អនុលោមតាមសំណើរបស់នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា" ព្រះរាជក្រឹត្យបានត្រាស់បង្គាប់ដូចខាងក្រោម:

> **មាត្រា ១:** ត្រូវបានលើកលែងទោសឱ្យលោក អៀង សារី អតីតឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការបរទេសក្នុងរដ្ឋាភិបាលនៃប្រទេសកម្ពុជាប្រជាធិបតេយ្យដែលត្រូវបានផ្តន្ទាទោស ប្រហារជីវិតបង់ និង រឹបអូសទ្រព្យសម្បត្តិទាំងអស់ តាមអំណាចសាលក្រមរបស់តុលាការប្រជាជនបដិវត្តក្រុងភ្នំពេញ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៩ និង ចំពោះទោសដែលបានកំណត់ដោយច្បាប់ស្តីពី ការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១/នស/៩៤ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៤។
>
> **មាត្រា ២:** ព្រះរាជក្រឹត្យនេះ មានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ។
>
> **មាត្រា ៣:** ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃនិង ក្រសួងយុត្តិធម៌ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសម្រេចជាស្ថាពរ។[២៦]

៥៦. ព្រះរាជក្រឹត្យនេះចូលជាធរមាននៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៩៦។

៥៧. អង្គបុរេជំនុំជម្រះយល់ឃើញថា អត្ថន័យនៃពាក្យ "លើកលែងទោស" មិនអាចកំណត់បានឡើយ ប្រសិនបើបកស្រាយដោយផ្អែកតាមវេយ្យាករណ៍។ ក្នុងន័យនេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ការប្រើប្រាស់ពាក្យខ្មែរសម្រាប់ពាក្យ "លើកទោស" ត្រូវបានប្រើប្រាស់ផ្ទុយគ្នា។ ពាក្យថា "លើកលែងទោស" នៅក្នុងប្រយោគទី១ នៃមាត្រា ១ គឺសសេរថា "ការលើកលែងទោស" ប៉ុន្តែ នៅក្នុងប្រយោគទី២ ពាក្យនេះសសេរថា "លើកលែងទោសពីការ

[២៦] សម្រង់នៅក្នុងសាលដីកានេះ គឺជាការបកប្រែន័យត្រង់ មកពីព្រះរាជក្រឹត្យជាភាសាខ្មែរ ដែលត្រូវបានបកប្រែដោយមន្ត្រីបកប្រែភាសាខ្មែរ-អង់គ្លេស ប្រចាំអង្គបុរេជំនុំជម្រះ។

ចោទប្រកាន់"។ "ការលើកលែងទោស" និង"ការលើកលែងទោសពីការចោទប្រកាន់" ទាំងពីរនេះ ដែលបានចែងនៅក្នុងព្រះរាជក្រឹត្យ មានភាពផ្ទុយគ្នានឹងបទបញ្ញត្តិស្តីពីការលើកលែងទោសតាមមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ អង្គបុរេជំនុំជម្រះ កត់សម្គាល់បន្ថែមទៀតថា នៅពេលដែលព្រះក្រឹត្យនេះបានប្រកាសឱ្យប្រើប្រាស់ ទោសប្រហារជីវិតត្រូវបានលុបចោល តាមស្មារតីនៃមាត្រា ៣២ នៃរដ្ឋធម្មនុញ្ញ។

៥៨. ក្រោយពីការពិចារណាជុំវិញបញ្ហាលើកលែងទោស ដែលពាក់ព័ន្ធនឹងការកាត់ទោសចំពោះបទប្រល័យពូជសាសន៍ អង្គបុរេជំនុំជម្រះពិចារណាឃើញថា សុពលភាពនៃការលើកលែងទោសមិនមានភាពប្រាកដជាក់លាក់។ ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា វាមិនបង្ហាញជាភស្តុតាងច្បាស់លាស់ថា នៅក្នុងផ្នែកនេះនៃព្រះរាជក្រឹត្យ នឹងរារាំងការកាត់ទោសចំពោះបទប្រល័យពូជសាសន៍ នៅចំពោះមុខ អ.វ.ត.ក។

៥៩. នៅក្នុងបរិបទនៃភាពផ្ទុយគ្នាចំពោះការប្រើប្រាស់ពាក្យលើកលែងទោស អង្គបុរេជំនុំជម្រះយល់ឃើញថា ចំពោះ "ទោស" នៅក្នុងប្រយោគទី២ នៃព្រះរាជក្រឹត្យ អាចត្រូវបានបកស្រាយថា ជនត្រូវចោទ "នឹងមិនអាចត្រូវតុលាការផ្តួចផ្តើមនីតិវិធីចោទប្រកាន់ចំពោះខ្លួនឡើយ" ដោយសារវាពាក់ព័ន្ធនឹងបញ្ហានៃការដាក់ទោស និងការរំលោភបំពានលើព្រះរាជក្រមលេខ១/នស/៩៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤។ អង្គបុរេជំនុំជម្រះនឹងលើកបញ្ហានេះឡើង តាមទិដ្ឋភាពនេះ ដោយសារតែការពន្យល់នេះគឺផ្តល់ផលប្រយោជន៍ល្អបំផុតចំពោះជនត្រូវចោទ។

៦០. នៅពេលអនុវត្តការបកស្រាយនាពេលនេះ អង្គបុរេជំនុំជម្រះនឹងត្រឡប់ទៅធ្វើការពិចារណាអំពីអានុភាពនៃផ្នែកនេះនៅក្នុងព្រះរាជក្រឹត្យ ដែលអាចកើតមានឡើង។

៦១. វិសាលភាពនៃផ្នែកនេះនៅក្នុងព្រះរាជក្រឹត្យ ត្រូវបានកម្រិតការចោទប្រកាន់ នៅក្រោមច្បាប់ដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ដែលប្រកាសឱ្យប្រើប្រាស់តាមស្មារតីព្រះរាជក្រមលេខ ១/នស/៩៤ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៤។ បទល្មើសទាំងឡាយ ដែលមានចែងនៅក្នុងច្បាប់នេះ មិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ អ.វ.ត.ក ឡើយ។ ដូច្នេះ អង្គបុរេជំនុំ

ជម្រះយល់ឃើញថា ផ្នែកនេះនៅក្នុងព្រះរាជក្រឹត្យ មិនអាចយល់ឃើញថាមានអានុភាពរាំងការកាត់ទោសដោយ អ.វ.ត.ក បានឡើយ។ ដូច្នេះ វាមិនបង្ហាញជាភស្តុតាងច្បាស់លាស់ថា ព្រះរាជក្រឹត្យ នឹងអាចរាំងការកាត់ទោសដោយ អ.វ.ត.ក។

៦២. នៅពេលពិចារណាសេចក្តីសន្និដ្ឋានទាំងនេះ អង្គបុរេជំនុំជម្រះនឹងមិនលើកឡើងសេចក្តីសន្និដ្ឋានរបស់ភាគីស្តីពីសុពលភាពនៃព្រះរាជក្រឹត្យ ទៀតឡើយ។[២៧]

៦៣. អង្គបុរេជំនុំជម្រះបានផ្តល់សម្អាងហេតុយ៉ាងច្រើនអំពី ហេតុអ្វីបានជាបញ្ហាស្តីពីគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (Ne bis in idem)* និងបញ្ហាអានុភាពនៃព្រះរាជក្រិត្យ ដែលអាចកើតមានឡើង មិនបង្ហាញជាភស្តុតាងច្បាស់លាស់ថា អាចរាំងការកាត់ទោស ដោយ អ.វ.ត.ក។ សរុបមក អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអាចប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន នៅក្នុងរឿងក្តីនេះ ក្នុងការបង្គាប់ការឃុំខ្លួនបណ្តោះអាសន្ន។

## ជំពូក ៥ - ភាពគ្រប់គ្រាន់នៃអង្គហេតុ ក្នុងការចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ស្របតាមវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង

៦៤. អង្គបុរេជំនុំជម្រះយល់ឃើញថា "ចៅក្រមមានកាតព្វកិច្ចត្រូវផ្តល់មូលហេតុនៅក្នុងសេចក្តីសម្រេច ដើម្បីផ្តល់យុត្តិកម្មចំពោះការបំពេញកិច្ចរបស់ខ្លួន។"[២៨]

---

[២៧] អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញបន្ថែមទៀតថា ការលើកលែងទោសគឺត្រូវបានកម្រិតត្រឹម "ការចោទប្រកាន់ក្រោមច្បាប់ដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ដែលប្រកាសដោយព្រះរាជក្រមលេខ ១/នស ៩៤ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៤" ហើយការលើកលែងទោសនេះមិនអាចអនុវត្តបានចំពោះរឿងក្តីនេះ។

[២៨] តុលាការអ៊ឺរ៉ុបផ្នែកសិទ្ធិមនុស្ស រឿងក្តី Suominen ទល់នឹង ប្រទេសហ្វាំងឡង់ដ៍ ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៣ វាក្យខណ្ឌទី ៣៦ គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីសង្កេតទូទៅ មាត្រា ១៤ វាក្យខណ្ឌទី ៤៩។ សូមអាន លិខិតឆ្លើយឆ្លងលេខ 903/1999 *Van Hulst ទល់នឹង ប្រទេសហូឡង់ដ៍* វាក្យខណ្ឌទី ៦(៤)។ លេខ 709/1996 *Bailey ទល់នឹង ប្រទេសចាម៉ៃកា* វាក្យខណ្ឌទី ៧(២)។ លេខ 663/1995 *Morrison ទល់នឹង ប្រទេសចាម៉ៃកា* វាក្យខណ្ឌទី ៨(៥)។ *រដ្ឋអាជ្ញា ទល់នឹង Milutinovic* រឿងក្តីលេខ IT-99-37-AR65.3 សេចក្តីសម្រេចបដិសេធសំណើសុំការអនុញ្ញាតប្តឹងឧទ្ធរណ៍របស់ Milutinovic ("*Milutinovic*") ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៣ វាក្យខណ្ឌទី ២២។ *រដ្ឋអាជ្ញា ទល់នឹង Furundzija* IT-95-17/1-A សេចក្តីសម្រេច ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ វាក្យខណ្ឌទី ៦៩។ នៅក្នុងរឿងក្តី *Milutinovic* អង្គជំនុំជម្រះសាលាដំបូងនៃICTY ពិចារណាឃើញថា "លក្ខខណ្ឌនេះតម្រូវឱ្យអង្គជំនុំជម្រះ បង្ហាញការយល់ឃើញរបស់ខ្លួនលើកត្តាពាក់ព័ន្ធទាំងអស់ ដែលគេរំពឹងថា អង្គជំនុំជម្រះសាលាដំបូងដែលយុត្តិធម៌ គួរតែពិចារណាលើកត្តាទាំងនេះ មុនពេលចេញសាលក្រម"។



PRETRIAL CHAMBER CHAMBRE PRÉLIMINAIRE ECCC CETC

00233028

E22/I/74



៦៥. នៅក្នុងដីកាបង្គាប់ការឃុំខ្លួនបណ្ដោះអាសន្ន សហចៅក្រមស៊ើបអង្កេតបានផ្ដល់ការយល់ឃើញលើលក្ខខណ្ឌនៃវិធាន ៦៣(៣)នៃវិធានផ្ទៃក្នុង ដោយយោងលើសំណុំរឿង ក្នុងកាលៈទេសៈទូទៅ និងកាលៈទេសៈដទៃទៀត។

៦៦. អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមិនមានកាតព្វកិច្ចផ្ដល់ការយល់ឃើញរបស់ខ្លួនលើកត្តាទាំងអស់ឡើយ ដោយសារកាតព្វកិច្ចនេះបង្ហាញថា សហចៅក្រមស៊ើបអង្កេតបានបង្ហាញអង្គច្បាប់ និងអង្គហេតុ ដែលត្រូវបានយកមកពិចារណាមុនពេលចេញសេចក្ដីសម្រេច។

## ជំពូក ៦ - ការពិនិត្យលើលក្ខខណ្ឌនៃវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង

៦៧. វិធាន៦៣(៣) នៃវិធានផ្ទៃក្នុង ចែងថា៖

សហចៅក្រមស៊ើបអង្កេត អាចចេញដីកាឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ បានតែក្នុងលក្ខខណ្ឌដូចខាងក្រោម៖

ក- មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

ខ- សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានការចាំបាច់ដើម្បី៖

(១) រារាំងកុំឱ្យជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។

(២) ថែរក្សាភស្តុតាង ឬការពារមិនឱ្យបំផ្លាញភស្តុតាង។

(៣) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី។

(៤) ការពារសន្តិសុខឱ្យជនដែលត្រូវចោទ ឬ

(៥) រក្សាសណ្ដាប់ធ្នាប់សាធារណៈ។

៦៨. នៅពេលពិចារណាបណ្ដឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះនឹងអនុវត្តការវិភាគរបស់ខ្លួន ដោយអនុវត្តតាមបទដ្ឋានដូចមានចែងនៅក្នុងវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង។

៦៩. នៅពេលសម្រេចថាតើមូលដ្ឋានចំពោះការឃុំខ្លួន ដូចមានចែងនៅក្នុងវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង បានបំពេញដែរឬទេ អង្គបុរេជំនុំជម្រះនឹងយកសារណាជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់របស់ភាគី ភស្តុតាងដែលបានដាក់ជូន និងសំណុំរឿងទាំងមូលរបស់សហចៅក្រមស៊ើបអង្កេត មកធ្វើការពិចារណា រហូតដល់ថ្ងៃសវនាការ។

**ក. <u>មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (វិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុង)</u>**

៧០. មុនពេលធ្វើការពិនិត្យលក្ខខណ្ឌនៃការឃុំខ្លួនដូចមានចែងនៅក្នុងវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះនឹងធ្វើការពិចារណាថាតើ ពិតជាមានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនជាប់ចោទធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែរឬទេ។

៧១. នៅពេលធ្វើការពិនិត្យថាតើ ពិតជាមានមូលហេតុដែលត្រូវបានរកឃើញដែរឬទេ អង្គបុរេជំនុំជម្រះនឹងធ្វើការសម្រេចលើអង្គហេតុ ឬព័ត៌មាន ដែលអាចធ្វើឱ្យអ្នកសង្កេតការណ៍ដោយមិនលម្អៀងជឿថា ជនជាប់ចោទធ្លាប់បានប្រព្រឹត្តបទល្មើស។[29] អនុលោមតាមមាត្រា ២៩ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ពាក្យថា "បានប្រព្រឹត្ត" ត្រូវបានយល់ថា ជាការបង្កឱ្យមានការទទួលខុសត្រូវជាលក្ខណៈបុគ្គល ដែលក្នុងនេះរួមបញ្ចូលទាំង ការរៀបចំផែនការ ញុះញង់ បញ្ជា ជួយ និងជម្រុញ ឬ ប្រព្រឹត្ត និងទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ថ្នាក់លើ។

៧២. នៅក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន សហចៅក្រមស៊ើបអង្កេតបានរកឃើញថា មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទ

---

[២៩] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាបង្គាប់ឃុំខ្លួនលោក នួន ជា បណ្តោះអាសន្ន កថាខណ្ឌទី ៤៦។

ល្មើសដូចខាងក្រោម ដែលបទល្មើសទាំងនេះត្រូវបានជូនដំណឹងដល់ជនត្រូវចោទក្នុងពេលចូលខ្លួនលើកដំបូង:

"- **បទល្មើសប្រឆាំងនឹងមនុស្សជាតិ** (មនុស្សឃាត ការសម្លាប់បំផុតពូជ ការដាក់ឃុំឃាំង ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ដទៃទៀត) និង

- ***ការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩*** (មនុស្សឃាតដោយចេតនា ការបង្កព្យសនកម្មធ្ងន់ធ្ងរ ឬការធ្វើឱ្យឈឺចាប់ខ្លាំងដោយចេតនាដល់រាងកាយ និងសុខភាព ការដកហូតដោយចេតនានូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ការនិរទេស ឬជម្លៀស ឬការបង្ខាំងជនស៊ីវិលដោយខុសច្បាប់)

បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៥ មាត្រា ៦ មាត្រា ២៩(ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

ជននេះត្រូវបានដាក់បន្ទុកថាបានប្រព្រឹត្ត នៅលើទឹកដីនៃប្រទេសកម្ពុជារវាង ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩:

- ក្នុងឋានៈជារដ្ឋមន្ត្រីក្រសួងការបរទេសដែលមានអំណាច និងការត្រួតពិនិត្យជាក់ស្តែងលើក្រសួងនេះ និងស្ថាប័នក្រោមចំណុះ និងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា
- បានញុះញង់ បញ្ជា ខកខានមិនបានទប់ស្កាត់ និងផ្តន្ទាទោស ឬម៉្យាងវិញទៀតបានសមគំនិតក្នុងការប្រព្រឹត្តបទល្មើសខាងលើ
- ដោយដឹកនាំ ជម្រុញ ដាក់ឱ្យដំណើរការ ឬផ្តល់ជំនួយក្រោមរូបភាពផ្សេងទៀតដល់នយោបាយ និងការអនុវត្តរបស់បក្សកុម្មុយនីស្តកម្ពុជាដែលចារឹកលក្ខណៈជា មនុស្សឃាត ការដាក់ឃុំឃាំង ការសម្លាប់បំផុតពូជ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ឬអំពើអមនុស្សធម៌ដទៃទៀត ដូចជាការជម្លៀសដោយបង្ខំ ការដាក់ជាទាសករ ឬការធ្វើការដោយបង្ខំ
- នៅក្នុងក្របខ័ណ្ឌនៃការវាយប្រហារជាទូទៅ និងជាប្រព័ន្ធ សំដៅលើជនស៊ីវិល
- ដោយកត់សម្គាល់ឃើញថា ក្នុងអំឡុងពេលទាំងអស់ ឬអំឡុងពេលណាមួយនៃចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ កម្ពុជាប្រជាធិបតេយ្យ



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. * C.E.T.C.

និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម ស្ថិតនៅក្នុងស្ថានភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិជាមួយគ្នា។"[៣០]

៧៣. ដោយសារដីកាបង្គាប់ឃុំខ្លួនរបស់សហចៅក្រមស៊ើបអង្កេត ផ្អែកលើបទចោទដែលមានវិសាលភាពកម្រិតជាងបទចោទដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរ អង្គបុរេជំនុំជម្រះនឹងប្រើប្រាស់វិសាលភាពដែលមានលក្ខណៈកម្រិតនេះ ដើម្បីពិនិត្យមើលដីកានេះ។

៧៤. អង្គបុរេជំនុំជម្រះជឿថា ពិតជាមានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា បទល្មើសជាក់លាក់ដែលកំពុងធ្វើការស៊ើបអង្កេតលើជនត្រូវចោទ ធ្លាប់ត្រូវបានប្រព្រឹត្តឡើង ជាផ្នែកមួយនៃការវាយប្រហារជាប្រព័ន្ធ និងជាទូទៅ ចំពោះជនស៊ីវិល ដោយសារមូលហេតុនៃការរើសអើង និង/ឬក្នុងបរិបទនៃជម្លោះប្រដាប់អាវុធអន្តរជាតិ។[៣១] ដូច្នេះ អង្គបុរេជំនុំជម្រះ នឹងធ្វើការពិនិត្យត្រឹមតែទំនួលខុសត្រូវជាលក្ខណៈបុគ្គលរបស់ជនត្រូវចោទតែប៉ុណ្ណោះ ដោយផ្អែកលើមាត្រា ២៩ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

៧៥. ជនត្រូវចោទបានទទួលស្គាល់ថា ខ្លួនជារដ្ឋមន្ត្រីក្រសួងការបរទេស យ៉ាងហោចណាស់ចាប់ពីថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៧៦ រហូតដល់ការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ។[៣២]

៧៦. តាមរបាយការណ៍ ជនត្រូវចោទបាននិយាយនៅក្នុងកិច្ចសម្ភាសជាមួយ Steve Heder ទៀតថា ខ្លួនគឺជាសមាជិកមួយរូបរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុនីស្តកម្ពុជាៈ

> "SH [Steve Heder]: អញ្ចឹង តើនរណាគេខ្លះជាសមាជិករបស់គណកម្មាធិការអចិន្ត្រៃយ៍ ហើយនរណាគេខ្លះចូលរួម ក្នុងពេលប្រជុំ?

---

[៣០] កំណត់ហេតុនៃការចូលខ្លួនដំបូង ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ D38 ទំព័រទី ៣។

[៣១] សូមអាន សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាបង្គាប់ឃុំខ្លួនលោក នួន ជា បណ្តោះអាសន្ន វាក្យខណ្ឌទី ៤៨ និងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាបង្គាប់ឃុំខ្លួនលោកស្រី អៀង ធីរិទ្ធិ បណ្តោះអាសន្ន ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨ C20/I/26 វាក្យខណ្ឌទី ២៤។ ។

[៣២] កំណត់ហេតុនៃការចូលខ្លួនដំបូង ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ D38 ទំព័រទី ២។

អ.ស [អៀង សារី]: សឹងតែសមាជិកទាំងអស់គ្នាដែលចូលរួមក្នុងការប្រជុំនេះ គឺរួមមាន ប៉ុល ពត នួន ជា សោ ភឹម ខ្ញុំ សុន សេន តាម៉ុក និង វ៉ន វ៉េត។"[៣៣]

៧៧. [លុបចោល][៣៤]

៧៨. [លុបចោល][៣៥ ៣៦]

៧៩. [លុបចោល][៣៧]

៨០. [លុបចោល][៣៨ ៣៩]

៨១. អង្គបុរេជំនុំជម្រះសង្កេតឃើញថា បញ្ជីអ្នកទោសនៅស-២១ បង្ហាញថា មនុស្សជាង១០០នាក់ត្រូវបានចាប់ខ្លួន"ពីក្រសួងការបរទេស"។[៤០]

៨២. នៅក្នុងសៀវភៅចំណងជើងថា "*Au dela du ciel, cinq chez les Khmer Rouges*" Laurence Picq ដែលជាអតីតបុគ្គលិករបស់ក្រសួងការបរទេស បានពិពណ៌នាអំពីការប្រជុំដែល តាមរបាយការណ៍ ជនត្រូវចោទបានញុះញង់បុគ្គលដទៃឱ្យ "កំទេចជនក្បត់"។ នៅក្នុងសៀវភៅ ដែលលើកឡើងផ្នែកពាក់ព័ន្ធនោះ សរសេរថា:

> " ក្នុងអំឡុងពេលប៉ុន្មានម៉ោងនោះ ខ្ញុំបានលឺ [អៀង សារី] និយាយអំពីការបន្សុទ្ធកម្ម ដែលបានកើតឡើងនៅក្នុងអឡុងពេលពីរបីសប្តាហ៍ចុងក្រោយនេះ។ "សត្រូវធំៗចំនួនប្រាំនាក់ត្រូវបានកំទេច:

---

[៣៣] សេចក្តីប្រកាសរបស់ជនសង្ស័យ អៀង សារី ហៅ វ៉ាន់ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៦ ERN 00003600-00003669 ទំព័រទី ២។

[៣៤] [លុបចោល]

[៣៥] [លុបចោល]

[៣៦] [លុបចោល]

[៣៧] [លុបចោល]

[៣៨] [លុបចោល]

[៣៩] [លុបចោល]

[៤០] សូមអាន D81 ឧបសម្ព័ន្ធ ក [លុបចោល]

ពួកក្រុម កុយ ធួន ដែលប្រធានភូមិភាគឧត្តរ, សៀ ឌឿន លេខាពាណិជ្ជកម្មរដ្ឋ ដែលជាប្តីរបស់ រឿន, តូច ភឿន សៀន អាន គ្រៀន លាន ដែលជាប្រធានអាកាសយានដ្ឋានពោធិចិនតុង និងប្រពន្ធរបស់គាត់, សៀន ឡាយនី និងប្រពន្ធរបស់គាត់... មនុស្សដែលខ្ញុំស្គាល់ និង ខ្ញុំគោរព។ (អ្វីដែលលោកអៀង សារីមិនបានរៀបរាប់ ក្នុងពេលថ្លែងសុន្ទរកថា គឺថា មុនពេលបញ្ជូនពួកគេទៅមន្ទីរសន្តិសុខ គាត់បានប្រកាសប្រាប់ពួកគេម្នាក់ៗថា ពួកគេនឹងត្រូវបានតម្លើងឋានៈ!)"

បន្ទាប់ពីលោក អៀង សារី បញ្ចប់ការថ្លែងសុន្ទរកថា លោក អៀង សារី មានទឹកមុខមាំ ហើយសុំឱ្យបងប្អូន ដែលចូលរួមសហការក្នុងការកំទេចខ្មាំង""។[៤១]

"កិច្ចប្រជុំបានបន្តទៀត។ លោក អៀង សារី បានបញ្ជាក់ថា បន្ទាប់ពីការចាប់ខ្លួនលើកចុងក្រោយ យើងនៅសល់សត្រូវរបស់យើងម្នាក់ទៀត ដែលមានឋានៈខ្ពស់។ នៅពេលយើងបានដឹងហើយនោះ យើងប្រាប់ខ្លួនឯងថា ដោយសារលោកអៀង សារី ស្គាល់សត្រូវម្នាក់នោះ គាត់នឹងទៅធ្វើអ្វីដែលចាំបាច់ ហើយបញ្ចប់វិសុទ្ធកម្មដែលគួរឱ្យស្អប់ និងរំខាននេះ។ ដល់ពេលយើងធ្វើអ្វីមួយជាក់លាក់ហើយ។ នៅពេលនេះ ទ័ពយើងបានប្រមូលផ្តុំនៅព្រំដែនហើយ តើគ្មានអ្វីដែលយើងធ្វើមិនកើតទៀតនោះ?

លោក អៀង សារី និយាយបន្តទៀតថាៈ

ខ្ញុំទុកឱ្យបងប្អូនស្វែងរកជនក្បត់ចុងក្រោយនេះ! លើកកំពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ និងកំទេចចោលអាក្បត់!"[៤២]

៨៣. អង្គបុរេជំនុំជម្រះសង្កេតឃើញបន្ថែមទៀតថា សំណុំរឿងរួមមាន*កំណត់ត្រាអំពីគណៈកម្មាធិការក្រសួងការបរទេស*។ យោងតាម "កំណត់ត្រាចំពោះឯកសារនេះ" របស់អ្នកកែសម្រួល និងអ្នកបកប្រែ Ben Kiernan និង ផាត កុសល កំណត់ត្រានេះ "ទំនង បញ្ជាក់ ថា ផ្នែកចំបងនៃអត្ថបទនេះ គឺជាកំណត់ហេតុសង្ខេបអំពីការថ្លែងសុន្ទរកថា និងឯកសារដែលបានរៀបចំ ឬចែកជូនដោយលោក អៀង សារី"។[៤៣] ក្នុងចំណោមផ្នែកនានា សៀវភៅសរសេរនៅក្នុងផ្នែកទី ៤ លើកឡើងអំពី "ការងារសំខាន់" ដែលការងារនេះជាផ្នែកមួយនៃ "គោល

[៤១] ការបកប្រែក្រៅផ្លូវការជាភាសាអង់គ្លេសនៃ Laurence Picq, *Au dela du Ciel, Cinq ans chez les Khmer rouges* ERN 00103372-00103478 ទំព័រទី ១០១។

[៤២] ការបកប្រែក្រៅផ្លូវការជាភាសាអង់គ្លេសនៃ Laurence Picq, *Au dela du Ciel, Cinq ans chez les Khmer rouges* ERN 00103372-00103478 ទំព័រទី ១២៣។

[៤៣] ផាត កុសល និង Ben Kiernan *របបអៀងសារីៈ សៀវភៅកំណត់ប្រចាំថ្ងៃនៃក្រសួងការបរទេសខ្មែរក្រហម ១៩៧៦-១៩៧៩* New Have: ១៩៩៨ ERN 00003237-00003341 ទំព័រទី ៣។

បំណងក្នុងការបង្ក្រាប់បញ្ហាដល់ការងាររបស់ក្រសួងការបរទេសចាប់ពីខែកក្កដា ឆ្នាំ១៩៧៦ ដល់ ខែកក្កដា ឆ្នាំ១៩៧៧":

" សត្រូវរបស់យើងកំពុងចុះអន់ថយនៅពេលនេះ ហើយនឹងស្លាប់។ បដិវត្តន៍បានដកឬស ហើយប្រព័ន្ធចារកម្មបានកំទេច។ ចំពោះវណ្ណៈវិញ សត្រូវរបស់យើងបានរត់ខ្ចាត់ខ្ចាយអស់ហើយ។ ប៉ុន្តែ ពួកគេនៅមានពួកចក្រព័ទ្ធអាមេរិក ពួកសេរី ពួកកាសេបេ និង ពួកវៀតណាម។ ទោះបីពួកនេះត្រូវបានវាយបង្ក្រាបក៏ដោយ ពួកនេះនៅអាចរារាំងយើងបានទៀត។ ចំនុចមួយទៀតគឺថា ខ្មាំងយើងគឺនៅបង្កប់ក្នុងអង្គភាពរបស់យើង ក្នុងជួរទាហាន ក្នុងជួរកម្មករ ក្នុងជួរសហករណ៍ និងក្នុងជួរបក្សរបស់យើង។ ដើម្បីធ្វើឱ្យបដិវត្តន៍យើងខ្លាំងក្លា យើងត្រូវបោះសម្អាតសត្រូវទាំងនេះជាដរាប ឱ្យបានលឿនតាមដែលយើងអាចធ្វើទៅបាន។"[៤៤]

៨៤. [លុបចោល][៤៥ ៤៦]

៨៥. [លុបចោល][៤៧]

៨៦. [លុបចោល][៤៨]

៨៧. [លុបចោល][៤៩]

៨៨. សំណុំរឿងរួមមានកំណត់ប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកម្មុនីស្តកម្ពុជា ដែលលើកឡើងអំពីវត្តមានរបស់ជនត្រូវចោទ យ៉ាងហោចណាស់នៅក្នុងពេលចំនួន៩ខុសៗគ្នា។[៥០]

---

[៤៤] ផាត កុសល និង Ben Kiernan *របបអៀងសារី: សៀវភៅកំណត់ប្រចាំថ្ងៃនៃក្រសួងការបរទេសខ្មែរក្រហម ១៩៧៦-១៩៧៩* New Have: ១៩៩៧ ERN 00003237-00003341 ទំព័រទី ៣ទំព័រទី ៩៥។

[៤៥] [លុបចោល]

[៤៦] [លុបចោល]

[៤៧] [លុបចោល]

[៤៨] [លុបចោល]

[៤៩] [លុបចោល]

[៥០] សូមអាន កំណត់ហេតុប្រជុំរបស់គណអចិន្ត្រៃយ៍នៃបក្សកម្មុយនីស្តកម្ពុជា ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ERN 00019108-00019126 ទំព័រទី ១។ កំណត់ហេតុប្រជុំរបស់គណអចិន្ត្រៃយ៍នៃបក្សកម្មុយនីស្តកម្ពុជា ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ERN 00019127-00019135 ទំព័រទី ១។ កំណត់ហេតុ

៨៩. តាមការចោទប្រកាន់ដែលមាននៅក្នុងចម្លើយរបស់ [លុបចោល] យើងអាចទាញការសន្និដ្ឋានបានថា ជនត្រូវចោទបានចូលរួមនៅក្នុងការធ្វើសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ជាពិសេសចំពោះបញ្ហាចាប់ខ្លួនរបស់ ស-២១ និងផលវិបាកនៃចម្លើយសារភាពនៅ ស-២១:

[លុបចោល][៥១]

៩០. [លុបចោល][៥២]

៩១. នៅក្នុងកិច្ចសម្ភាសជាមួយអ្នកកាសែតនៅក្នុងខែកញ្ញា ឆ្នាំ១៩៩៦ កាសែត *Phnom Penh Post* បានលើកឡើងថា នៅពេលសួរជនត្រូវចោទថាតើ នៅពេលនោះ គាត់ដឹងអ្វីផ្សេងក្រៅពីនេះ ចំពោះការសម្លាប់ ការបោសសម្អាតនៅក្នុងបក្ស អ្វីដែលអ្នកដឹងដោយខ្លួនឯងផ្ទាល់ ដែរឬទេ ជនត្រូវចោទឆ្លើយថា:

> "ប៉ុល ពត ឆ្លាតណាស់ ដោយបានបង្កើតគណៈកម្មាធិការសម្ងាត់មួយ។ ជួនកាល ពួកគេសម្លាប់ហើយ ទើបគាត់មកប្រាប់ខ្ញុំ។"[៥៣]

៩២. យោងតាមបញ្ជីអ្នកទោសនៅ ស-២១ ដែលបានលើកឡើងខាងលើ ចម្លើយសារភាពរបស់ [លុបចោល] ដែលអ្នកទាំងពីរនេះត្រូវបានចាប់ខ្លួនពីក្រសួងការបរទេស បានបង្ហាញថា ចម្លើយ សារភាពបានបញ្ជូនទៅជនត្រូវចោទ។[៥៤] [លុបចោល][៥៥]

---

ប្រជុំរបស់គណអចិន្ត្រៃយ៍នៃបក្សកម្មុយនីស្តកម្ពុជា ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ERN 00019127-00019135 ទំព័រទី ១។ កំណត់ហេតុប្រជុំរបស់គណអចិន្ត្រៃយ៍នៃបក្សកម្មុយនីស្តកម្ពុជា ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ ERN 00000713-00000720 ទំព័រទី ១។ កំណត់ហេតុប្រជុំរបស់គណអចិន្ត្រៃយ៍នៃបក្សកម្មុយនីស្តកម្ពុជា ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ ERN 00017124-00017127 ទំព័រទី ១។ កំណត់ហេតុប្រជុំរបស់គណអចិន្ត្រៃយ៍នៃបក្សកម្មុយនីស្តកម្ពុជា ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦ ERN 00000736-00000743 ទំព័រទី ១។ កំណត់ហេតុប្រជុំរបស់គណអចិន្ត្រៃយ៍នៃបក្សកម្មុយនីស្តកម្ពុជា ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៧៦ ERN 00000768-00000769 ទំព័រទី ១។ កំណត់ហេតុប្រជុំរបស់គណអចិន្ត្រៃយ៍នៃបក្សកម្មុយនីស្តកម្ពុជា *ស្តីពីការពិនិត្យលើប្រតិកម្មរបស់វៀតណាមនៅក្នុងកិច្ចប្រជុំលើកទី៥* ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៧៦ ERN 00000810-00000826 ទំព័រទី ១។ កំណត់ហេតុប្រជុំរបស់គណអចិន្ត្រៃយ៍នៃបក្សកម្មុយនីស្តកម្ពុជា ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៧៦ ERN 00000829-00000836 ទំព័រទី ១។

[៥១] [លុបចោល]

[៥២] [លុបចោល]

[៥៣] សេចក្តីប្រកាសរបស់ជនសង្ស័យ អៀង សារី ហៅ វ៉ាន់ ចុះថ្ងៃទី៦ ដល់ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៩៦ ERN 00078605-00078618 ទំព័រទី ៧។

៩៣. និយាយឱ្យជាក់ជាងនេះ នៅក្នុងសៀវភៅចំណងជើងដែលបានលើកឡើងខាងលើ Laurence Picq និងសាក្សី [លុបចោល] បាននិយាយថា ជនត្រូវចោទមានចម្លើយសារភាពនៅ ស-២១ របស់អ្នកទោស [លុបចោល]។[៥៦]

៩៤. ក្រោយពីពិចារណាឯកសារទាំងឡាយដែលបានលើកឡើងខាងលើ អង្គបុរេជំនុំជម្រះយល់ឃើញថា សំណុំរឿងរួមមានភស្តុតាង ដែលអាចធ្វើឱ្យអ្នកសង្កេតការណ៍ដោយមិនលម្អៀងជឿថា នៅក្នុងដំណាក់កាលស៊ើបអង្កេត ជនត្រូវចោទធ្លាប់បានប្រព្រឹត្តបទល្មើសជាក់លាក់ដែលខ្លួនកំពុងស្ថិតនៅក្រោមការស៊ើបអង្កេត។ ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា លក្ខខណ្ឌតម្រូវនៃវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង បានបំពេញ។

**ខ.** <u>ការពិចារណាលើលក្ខខណ្ឌដែលធ្វើឱ្យការសម្រេចឃុំខ្លួនបណ្ដោះអាសន្នជាវិធានការមួយចាំបាច់ (វិធាន ៦៣(៣)(ខ)នៃវិធានផ្ទៃក្នុង)</u>

*១. លក្ខខណ្ឌទីមួយ និងទីពីរ នៅក្នុងវិធាន ៦៣(៣)(ខ)នៃវិធានផ្ទៃក្នុងចែងថា: ដើម្បីរារាំងកុំឱ្យជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ និងដើម្បីថែរក្សាភស្តុតាង ឬការពារមិនឱ្យបំផ្លាញភស្តុតាង”*

៩៥. លក្ខខណ្ឌនៃការសម្រេចឃុំខ្លួនបណ្ដោះអាសន្នទាំងពីរនេះ អាចយកមកវាយតម្លៃរួមគ្នា ដោយសារលក្ខខណ្ឌទាំងពីរនេះមានទឡ្ហីករណ៍គាំទ្រដូចគ្នា។ ចម្លើយរបស់សាក្សីត្រូវបានយកមកធ្វើការពិចារណាថាជា “ភស្តុតាង” ក្នុងអត្ថន័យនៃវិធាន ៦៣(៣)(ខ)(២) នៃវិធានផ្ទៃក្នុង។

---

[៥៤] ចម្លើយសារភាពនៅស-២១ របស់ [លុបចោល] ERN 00024493-00024557។ ចម្លើយសារភាពនៅស-២១ របស់ [លុបចោល] ERN 00004773-00004827, ERN 00002465-00002472, ERN 00026191-00026252។ ចម្លើយសារភាពនៅស-២១ របស់ [លុបចោល] ERN 00023010-00023030, ERN 00022924-00022943។

[៥៥] [លុបចោល]

[៥៦] [លុបចោល]

៩៦. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សំណុំរឿងទាំងមូលបានផ្ដល់ជូនជនត្រូវចោទ ដោយនៅក្នុងនោះរួមមានឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីសំខាន់ៗ។ យើងហាក់ដូចជាដឹងហើយថា សាក្សីមួយចំនួនតិចណាស់ដែលនៅរស់ ហើយអាចផ្ដល់សក្ខីកម្មអំពីការពាក់ព័ន្ធរបស់ជនត្រូវចោទនឹងបទល្មើសដែលដាក់បន្ទុកមកលើខ្លួន។ សាក្សីទាំងនេះ មិនទាន់បានសហចៅក្រមស៊ើបអង្កេតធ្វើការស្ដាប់ចម្លើយនៅឡើយ។

៩៧. ជនត្រូវចោទបានឆ្លើយថា ខ្លួនធ្លាប់ជារដ្ឋមន្ត្រីក្រសួងការបរទេស ក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ។ បន្ថែមពីនេះ ដូចដែលបានលើកឡើងខាងលើ យើងអាចទាញការសន្និដ្ឋានចេញពីចម្លើយរបស់ ជនត្រូវចោទ ខៀវ សំផន និង នួន ជា បានយ៉ាងត្រឹមត្រូវថា ជនត្រូវចោទ ជាសមាជិករបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្ដកម្ពុជា។ ជនត្រូវចោទហាក់ដូចជាមានភាពសកម្មនៅក្នុងការងារនយោបាយ បន្ទាប់ពីឆ្នាំ១៩៧៩។[៥៧] អង្គបុរេជំនុំជម្រះយល់ឃើញថា កម្រិតនៃឥទ្ធិពលគឺចាំបាច់ នៅជាប់នឹងមុខតំណែងជាន់ខ្ពស់ទាំងនេះ និងការពាក់ព័ន្ធនៅក្នុងចលនានយោបាយ។ ឥទ្ធិពលនេះមិនបានរលត់នៅឡើយ នៅពេលដែលបុគ្គលម្នាក់លែងកាន់កាប់មុខតំណែងទាំងនេះទៅហើយ។ ហេតុដូច្នេះហើយ ឥទ្ធិពលនេះ អាចនៅតែមាននាពេលសព្វថ្ងៃនេះ។

៩៨. ក្នុងកាលៈទេសៈទាំងនេះ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ជនត្រូវចោទមានឥទ្ធិពលសំខាន់ ក្នុងការរៀបចំបុគ្គលដទៃឱ្យធ្វើការគាបសង្កត់លើសាក្សី និងជនរងគ្រោះ។

៩៩. ទោះបីជាយ៉ាងនេះក៏ដោយ អង្គបុរេជំនុំជម្រះមិនឃើញមានភស្ដុតាងស្ដីពី សកម្មភាពអតីតកាល និង/ឬអាកប្បកិរិយារបស់ជនត្រូវចោទ ដែលអាចបង្ហាញហានិភ័យជាក់ស្ដែងមួយថា ជនត្រូវចោទអាចប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនក្នុង ការគាបសង្កត់សាក្សី និងជនរងគ្រោះ។

---

[៥៧] ធេក សម្បត្តិ និង Erika Kinetz "ក្រុមហ៊ុនសាជីវកម្មរបស់ខ្មែរក្រហម៖ អតីតជនកុម្មុយនីស្ដ ក្រសោបយកសេដកិច្ចទីផ្សារនៅក្នុងស្រុកម៉ាឡៃ" *ខឹមបូឌា ដេលី* ចុះថ្ងៃទី១៧ ដល់ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៧ (សេចក្ដីជូនដំណឹងអំពីការលាតត្រដាងឯកសារ និង ឯកសារសម្អាងផ្លូវច្បាប់បន្ថែម ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៧ D29 ឯកសារភ្ជាប់លេខ ៣៦)។

១០០. ដូច្នេះ ការឃុំខ្លួនមិនមែនជាវិធានការចាំបាច់មួយ ដើម្បីរាំងជនត្រូវចោទកុំឱ្យធ្វើការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ និងបំផ្លាញភស្តុតាងឡើយ។

*២. លក្ខខណ្ឌទីបី នៅក្នុងវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុងចែងថា: ដើម្បីធានាអំពីវត្តមាន របស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី។*

១០១. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ដោយយល់ឃើញពីភាពធ្ងន់ធ្ងរនៃបទចោទ ជនត្រូវចោទអាចប្រឈមនឹងការទទួលទោសជាប់ពន្ធនាគារពីរយៈពេលប្រាំ(៥)ឆ្នាំ ដល់ អស់មួយជីវិត ក្នុងករណីរកឃើញថា ខ្លួនមានពិរុទ្ធភាព។

១០២. ភស្តុតាងបានចង្អុលបង្ហាញថា រហូតមកទល់ឆ្នាំ១៩៩៦ ជនត្រូវចោទបានរស់នៅក្នុងក្រុងប៉ៃលិន ក្រុងគាំទ្រដល់ខ្មែរក្រហម ដែលនៅកៀកនឹងព្រំប្រទល់ប្រទេសថៃតែម្តង។ ទោះបីជាក្រោយពេលជនត្រូវចោទផ្លាស់មករស់នៅក្នុងទីក្រុងភ្នំពេញក៏ដោយ ជនត្រូវចោទ នៅពេលខ្លះនៅតែបន្តទៅលេងក្រុងប៉ៃលិន។[៥៨] បន្ថែមលើចំនុចនេះ ភស្តុតាងបញ្ជាក់ថា ជនត្រូវចោទមានទំនាក់ទំនងនៅក្រុងប៉ៃលិន គឺជាមួយលោកអភិបាលក្រុង និងអភិបាលរង។[៥៩] ទំនាក់ទំនងទាំងនេះ ទំនងអាចជួយជ្រោមជ្រែងដល់ជនត្រូវចោទ ក្នុងករណីខ្លួនមានបំណងចង់រត់គេចខ្លួន។ បុគ្គលទាំងពីរនេះ អាចជួយយ៉ាងពិតប្រាកដដល់ជនត្រូវចោទ ក្នុងការសុំបណ្ណពិសេស ដើម្បីឆ្លងកាត់ច្រកព្រំដែនថៃ។ ហើយស្ថានភាពនេះទំនងណាស់ថា បុគ្គលដែលមានឥទ្ធិពលទាំងនេះត្រូវបានគេទទួលស្គាល់យ៉ាងច្រើននៅក្នុងតំបន់នោះ គឺនៅក្នុងព្រំប្រទល់ទាំងសងខាង ដែលអាចផ្តល់លទ្ធភាពដល់ជនត្រូវចោទក្នុងការរត់គេចខ្លួន។

១០៣. អង្គបុរេជំនុំជម្រះ ក៏កត់សម្គាល់ឃើញផងដែរថា ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ ទាំងជនត្រូវចោទរូបនេះ និងប្រពន្ធរបស់ខ្លួន បានធ្វើដំណើរទៅបរទេសជាញឹក

---

[៥៨] កែត សំរេច "អៀង សារី នៅស្ងៀម ខណៈ នួន ជា និង ខៀវ សំផន កំពុងព្យាយាមប្រកាសជាសាធារណៈថា ខ្លួនមិនបានដឹងអំពីឧក្រិដ្ឋកម្មក្នុងរបប"វាលពិឃាដ" *មនសិការខ្មែរ* ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧ (D29 ឯកសារភ្ជាប់លេខ ៨("អត្ថបទចំណងជើងថា "អៀង សារី នៅស្ងៀម""។ អត្ថបទគ្មានចំណងជើង *មនសិការខ្មែរ* ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៦ (D29 ឯកសារភ្ជាប់លេខ ៥១។)

[៥៩] អត្ថបទចំណងជើងថា "អៀង សារី នៅស្ងៀម"។

ញាប់។[៦០] ដោយពិចារណាឃើញថា ការចំណាយដ៏សន្ធឹកសន្ធាប់យ៉ាងជាក់ស្តែងលើការធ្វើដំណើរកាលពីអតីតទាំងនេះ យើងអាចទាញការសន្និដ្ឋានថា ជនត្រូវចោទមានមធ្យោបាយផ្នែកថវិកា ឬទទួលបានមធ្យោបាយទាំងនេះ ដើម្បីជួយសម្រួលដល់ការរត់គេចខ្លួនបាន។

១០៤. ជនត្រូវចោទមានលិខិតឆ្លងដែន តាំងពីពេលផ្តាច់ខ្លួននៅក្នុងឆ្នាំ១៩៩៦ មកម្លេះ។[៦១] មិនតែប៉ុណ្ណោះ តាមរបាយការណ៍បានបង្ហាញថា ជនត្រូវចោទមានលិខិតឆ្លងដែនចិន ដែលមានឈ្មោះក្លែងក្លាយ និងទីកន្លែងកំណើតដែលមិនត្រឹមត្រូវ។[៦២] កំណត់ហេតុជាលាយលក្ខណ៍អក្សរ នៃការចូលខ្លួនដំបូងបង្ហាញថា ជនត្រូវចោទបានកែថ្ងៃកំណើត និងទីកន្លែងកំណើតរបស់ខ្លួនតាំងពីដំបូងមកម្លេះ។[៦៣] ដោយពិចារណាលើអតីតតួនាទីនយោបាយរបស់គាត់ ជនត្រូវចោទមានសម្ព័ន្ធភាពនៅឯបរទេស ដែលអាចផ្តល់លទ្ធភាពដល់ខ្លួនក្នុងការធ្វើដំណើរទៅប្រទេសទាំងនោះបាន។

១០៥. ដោយសារវាជាការពិតដែលថា ជនត្រូវចោទបានដឹងថា សហគមន៍ជាតិ និងអន្តរជាតិ បានរៀបចំសាលាក្តីមួយនេះឡើង ក្នុងគោលបំណងធ្វើការចោទប្រកាន់ យ៉ាងហោចណាស់ មេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ ហើយដោយសារ វាជាការពិតថា ជនត្រូវចោទ ប្រហែលជាព្យាយាមរត់គេចខ្លួនមុន ស្ថានភាពនាពេលនេះ មិនដូចស្ថានភាពពីមុនឡើយដែល នាពេលនេះ ជនត្រូវចោទកំពុងស្ថិតនៅក្រោមការស៊ើបអង្កេតនៅចំពោះមុខ អ.វ.ត.ក។ ម្យ៉ាងវិញទៀត ជនត្រូវ

---

[៦០] អត្ថបទចំណងជើងថា "អៀង សារី នៅស្ងៀម"។ ផាន់ អាណា និង Kevin Doyle "ជនគម្រូវដែលបានចូលនិវត្តន៍: នៅក្នុងវ័យចំណាស់ លោក អៀង សារី ជួបប្រទះនឹងការដកហូតទ្រព្យសម្បត្តិពីរបបបដិវត្តន៍" *ឌឹ ខែមបូឌៀ ដេលី* ថ្ងៃទី៥ ដល់ ថ្ងៃទី ៦ ខែតុលា ឆ្នាំ២០០២ (D29 ឯកសារភ្ជាប់លេខ ១២)។ Michael Sheridan "បងប្អូនថ្លៃរបស់លោក ប៉ុល ពត ប្រឈមនឹងការកាត់ទោស" *ឌឹ សាន់ដេ ថែម* ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៦ (D29 ឯកសារភ្ជាប់លេខ ១៣)។ អត្ថបទគ្មានចំណងជើង *មនសិការខ្មែរ* ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៦ (D29 ឯកសារភ្ជាប់លេខ ៥១)។ Kathy Marks "តើ "បងធំទី៣" ដែលជាស្ថាបនិកនៃវាលពិឃាត រស់នៅក្នុងជីវិតដ៏អើតឆាយ ក្នុងប្រទេសកម្ពុជានាសម័យថ្មី តាមរបៀបណា" *ឌឹ អ៊ីនឌីផេនដេន* ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០២ (D29 ឯកសារភ្ជាប់លេខ ៥២)។

[៦១] "អតីតមេដឹកនាំខ្មែរក្រហមតម្រង់ជួរសុំលិខិតឆ្លងដែន - របាយការណ៍" Agence France Presse ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០០ (D29 ឯកសារភ្ជាប់លេខ ៥៤)។ "លិខិតឆ្លងដែនការទូតរបស់អតីតរដ្ឋមន្ត្រីការបរទេសនៃរបបខ្មែរក្រហមត្រូវបានដកហូត" *Reuters News* ចុះថ្ងៃទី៧ ខែមករា ឆ្នាំ២០០២ (D29 ឯកសារភ្ជាប់លេខ ៥៥)។

[៦២] សូមអាន លិខិតឆ្លងដែនចិន ច្បាប់ថតចម្លង របស់លោក អៀង សារី (D29 ឯកសារភ្ជាប់លេខ ១៧) និង ឆាង យុក "តើអៀង សារី ជានរណាពិតប្រាកដ?" *ឌឹ ខែមបូឌា ដេលី* ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៩៨ (D29 ឯកសារភ្ជាប់លេខ ១៨)។

[៦៣] កំណត់ហេតុនៃការចូលខ្លួនដំបូង D38 ទំព័រទី ១ និង ទំព័រទី ២។

00233040

E22/I/74



ចោទប្រហែលមិនដែលគិតឃើញថា ខ្លួនប្រហែលជាស្ថិតនៅក្នុងចំណោមជនសង្ស័យដំបូង ដែលត្រូវ អ.វ.ត.ក ចាប់ខ្លួនឡើយ។ ក្នុងករណីនេះ អង្គបុរេជំនុំជម្រះក៏បានកត់សម្គាល់ផងដែរ លើបញ្ហានៃការជំនុំជម្រះក្នុងឆ្នាំ១៩៧៩ និបញ្ហាលើកលែងទោស ដែលជនត្រូវចោទទទួលបាន តាមអំណាចនៃព្រះរាជក្រឹត្យ។

១០៦. ដោយផ្អែកលើហេតុផលទាំងនេះ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ការសម្រេចឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការចាំបាច់មួយ ដើម្បីធានាអំពីវត្តមានរបស់ជនត្រូវចោទក្នុងកិច្ចដំណើរការនីតិវិធី។

*៣. លក្ខខណ្ឌទីបួន នៅក្នុងវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុងចែងថា: ដើម្បីការពារសន្តិសុខឱ្យជនដែលត្រូវចោទ*

១០៧. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ជនត្រូវចោទគឺជាអតីតអ្នកនយោបាយមួយដែលគេស្គាល់គ្រប់ៗគ្នា នៅក្នុងប្រទេសកម្ពុជា ហើយត្រូវបានគេចាត់ទុកថា ជាមេដឹកនាំមួយរូបក្នុងចំណោមមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ។

១០៨. អង្គហេតុដែលថា ក្នុងរយៈពេល១០ឆ្នាំចុងក្រោយ ជនត្រូវចោទ មានទីលំនៅស្ថិតនៅក្នុងទីក្រុងភ្នំពេញ ដោយគ្មានអំពើហិង្សាណាមួយតវ៉ាចំពោះសេរីភាពរបស់ខ្លួន ឬការប៉ុនប៉ងសងសឹក គឺមានការពាក់ព័ន្ធតិចតួច។ យើងគួរយល់ថា ការដែលគ្មានអំពើហិង្សា និងការប៉ុនប៉ងសងសឹកទាំងអស់នេះ គឺដោយសារវាស្ថិតក្នុងបរិបទនៃនិទណ្ឌភាពដែលកើតមានក្នុងសង្គមនេះអស់រយៈពេលសាមសិបឆ្នាំ ហើយ ជាពិសេស អាចយកមកអនុវត្តចំពោះជនត្រូវចោទនេះ ដែលទទួលបានការលើកលែងទោសនៅក្នុង ឆ្នាំ១៩៩៦។ ដោយសារករណីនេះ វាទំនងថា ការចាប់ខ្លួនជនត្រូវចោទ ធ្វើឱ្យសុវត្ថិភាពលើរូបគាត់ មានការថយចុះ។

១០៩. នៅពេលយកការគំរាមកំហែង ដែលត្រូវបានគេរាយការណ៍ថា បានកើតឡើងចំពោះខុច ក្នុងអំឡុងពេលសវនាការរបស់អង្គបុរេជំនុំជម្រះ មកធ្វើការពិចារណា អង្គបុរេជំនុំជម្រះយល់



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE ECCC CETC

ឃើញថា បន្ទាប់ពីបានបង្ហាញមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់ថា ជនត្រូវចោទធ្លាប់ប្រព្រឹត្តបទល្មើស ដែលពាក់ព័ន្ធនឹងបទល្មើសដែល ឌុច ត្រូវបានចោទប្រកាន់ ការគម្រាមកំហែងនេះ ក៏អាចកើតឡើងចំពោះជនត្រូវចោទរូបនេះដែរ។[៦៤]

១១០. អង្គបុរេជំនុំជម្រះពិចារណាឃើញថា ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការមួយចាំបាច់ដើម្បីការពារសុវត្ថិភាពរបស់ជនត្រូវចោទ។

*៤. លក្ខខណ្ឌទីប្រាំ នៅក្នុងវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុងចែងថា: ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ*

១១១. ដូចដែលបានផ្តល់សម្អាងហេតុនៅក្នុងសាលដីកាមុនរបស់អង្គបុរេជំនុំជម្រះ និងអនុលោមតាមតុលាការអ៊ឺរ៉ុបផ្នែកសិទ្ធិមនុស្ស នៅក្នុងរឿងក្តី *Letellier,* ដើម្បីបំពេញលក្ខខណ្ឌនេះ "អង្គហេតុដែលអាចបង្ហាញថា ការដោះលែងជនត្រូវចោទ ពិតជាអាចប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ត្រូវតែបង្ហាញថាមានអត្ថិភាព ។ ម្យ៉ាងទៀត ការសម្រេចឃុំខ្លួននឹងនៅបន្តស្របច្បាប់ ក្នុងករណីដែលសណ្តាប់ធ្នាប់សធារណៈ ពិតនៅតែជាការគម្រាមកំហែងមែននោះ។[...]"[៦៥] អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញពីភាពខុសគ្នារវាងបទដ្ឋាននៃ "អង្គហេតុដែលអាចបង្ហាញអង្គហេតុ" និងបទដ្ឋានដែលសហមេធាវីការពារក្តីបានអះអាងគឺ "អង្គហេតុ ដែលបង្ហាញ"។[៦៦]

---

[៦៤] Erika Kinetz និង យន់ សាមៀន "ឌុចបង្ហាញខ្លួនចំពោះមុខចៅក្រម នៅក្នុងសវនាការជាសាធារណៈលើកទី១ របស់អវតក" *ឌឹ ខែមបូឌៀ ដេលី* ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ (សេចក្តីសន្និដ្ឋានតបនឹងបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំចំពោះដីកាបង្គាប់ការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧ C11/11 ឧបសម្ព័ន្ធក ឯកសារភ្ជាប់លេខ ក ២៤)។

[៦៥] សាលដីកាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចការឃុំខ្លួន នួន ជា បណ្តោះអាសន្ន កថាខណ្ឌទី៧៦ យោងលើតុលាការអ៊ឺរ៉ុបផ្នែកសិទ្ធិមនុស្ស រឿងក្តី Letellier ទល់នឹង បារាំង ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩១ កថាខណ្ឌទី ៥១។

[៦៦] សារណាបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ចំពោះដីកាបង្គាប់ការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ២០០៨ C22/I/5 វាក្យខណ្ឌទី ១១។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

១១២. អង្គបុរេជំនុំជម្រះយល់ឃើញថា ទោះបីភស្តុតាងជាក់លាក់តម្រូវឱ្យយកមកគាំទ្រលើហានិភ័យជាក់ស្តែងមួយដែលថា សណ្តាប់ធ្នាប់សាធារណៈ អាចធ្វើឱ្យរំជើបរំជួលប្រសិនបើធ្វើការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំបណ្តោះអាសន្នក៏ដោយ ក៏ការវាយតម្លៃបែបនេះ ចាំបាច់ត្រូវពាក់ព័ន្ធនឹងវិធានការទស្សន៍ទាយ ជាពិសេសនៅក្នុងក្របខណ្ឌនៃឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក។[៦៧]

១១៣. អង្គបុរេជំនុំជម្រះយល់ឃើញថា ពេលវេលាដែលបានកន្លងផុតទៅនោះ មិនបានបន្ថយឥទ្ធិពលនៃរបបកម្ពុជាប្រជាធិបតេយ្យលើសង្គមខ្មែរឡើយ។ ប្រជាជនមួយចំនួន ដែលធ្លាប់រស់នៅក្នុងរយៈពេលចាប់ពី ឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ត្រូវបានគេជឿថា បានទទួលរងនូវជំងឺបាក់ស្បាត។ អ្នកជំនាញនានាបាននិយាយថា ការចាប់ផ្តើមកិច្ចតុលាការនៅចំពោះមុខ អ.វ.ត.ក "អាចបង្កគ្រោះថ្នាក់ថ្មីស្រឡាងមួយដល់សង្គមកម្ពុជា" ហើយអាច "ធ្វើឱ្យក្តីកង្វល់កើតឡើងវិញ"។ ហើយ ការចាប់ផ្តើមកិច្ចតុលាការនៅចំពោះមុខ អ.វ.ត.ក ធ្វើឱ្យកើនឡើងនូវផលវិបាកអវិជ្ជមានលើសង្គមឡើងវិញ ដែលអាចកើតឡើងព្រមគ្នាជាមួយក្តីកង្វល់នេះ។[៦៨]

១១៤. មហាសន្និបាតអង្គការសហប្រជាជាតិបានទទួលស្គាល់ថា ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អំឡុងចាប់ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ នៅតែជាបញ្ហាបង្កឱ្យមានការព្រួយបារម្ភចំពោះសង្គមកម្ពុជា និងមនុស្សជាតិ:

> "បានរំលឹកថា ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរចំពោះច្បាប់កម្ពុជា និងច្បាប់អន្តរជាតិក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ នៅតែជាបញ្ហាបង្កឱ្យមានការព្រួយបារម្ភធ្ងន់ធ្ងរដល់សហគមន៍អន្តរជាតិទាំងមូល
>
> [...]

---

៦៧ ដូចការអនុវត្តនៅក្នុង*ស្ថានភាពនៅក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ ក្នុងរឿងក្តី រដ្ឋអាជ្ញា ទល់នឹង ថូម៉ាស លូប៊ែងហ្គា ឌីអ៊ីឡូ* 01/04-01/06(OA 7) "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ថូម៉ាស លូប៊ែងហ្គា ឌីអ៊ីឡូ ប្រឆាំងនឹងសាលដីការបស់អង្គបុរេជំនុំជម្រះ" អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ២០០៧ កថាខណ្ឌទី ១៣៧។

៦៨ Rob Savage "ជំងឺបាក់ស្បាត: កេរតំណែលនៃការឈឺចាប់ និងអំពើហិង្សា" South Eastern Globe ប្រចាំខែ ចុះខែកក្កដា ឆ្នាំ២០០៧ ទំព័រទី ២៤ - ទី២៧ (C11/11 ឧបសម្ព័ន្ធ ក ឯកសារភ្ជាប់លេខ ក ២៥ ។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

> បានទទួលស្គាល់ថា ការទទួលខុសត្រូវរបស់ចារីនីមួយៗចំពោះការរំលោភបំពានសិទ្ធិមនុស្ស យ៉ាងធ្ងន់ធ្ងរ គឺជាសមាសធាតុដែលមានប្រសិទ្ធិភាពមួយក្នុងចំណោមសមាសធាតុចំបងទាំងឡាយ ក្នុងការផ្តល់សំណងដល់ជនរងគ្រោះ [...]"[៦៩]

១១៥. សវនាការនៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយក្នុងនោះរួមទាំងសវនាការលើជនត្រូវចោទរូបនេះផងនោះ បានបង្កើតជាចំណាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់ប្រជាជនកម្ពុជា និងសារពត៌មានទាំងឡាយ ព្រមទាំងសហគមន៍អន្តរជាតិនានាផងដែរ។ ប្រជាជនរាប់រយនាក់ ក្នុងនោះរួមមានសាធារណៈជន អ្នកតំណាងផ្នែកសារព័ត៌មាន អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍អន្តរជាតិនានា បានមកចូលរួមក្នុងពេលសវនាការនេះ។ ការចាប់អារម្មណ៍នេះ គឺជាការបង្ហាញពីការពិតមួយដែលថា ដំណើរការក្តីលើជនសង្ស័យដែលគេចោទថាជាមេដឹកនាំជាន់ខ្ពស់ និងបុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ សូម្បីត្រឹមតែដំណាក់កាលមុនអង្គសេចក្តីប៉ុណ្ណោះ នៅតែជាបញ្ហាបង្កឱ្យមានការព្រួយបារម្ភធ្ងន់ធ្ងរដល់ប្រជាជនកម្ពុជា និងសហគមន៍អន្តរជាតិ នាពេលបច្ចុប្បន្ន។

១១៦. អង្គបុរេជំនុំជម្រះ សង្កេតឃើញថា ការគម្រាមកំហែងចំពោះបញ្ហាសន្តិសុខ គឺមិនមែនជាការបំភ័ន្តភ្នែកទេ។ ករណីទីមួយ ការគម្រាមកំហែងនេះអាចស្តែងចេញតាមរយៈការធ្វើឱ្យជ្រួលច្របល់ជារៀងរាល់ថ្ងៃ ឬក៏បង្កឱ្យមានបទល្មើសហិង្សាជាដើម ដែលរូបភាពទាំងនេះត្រូវបានអង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញតាមការយល់ដឹងជាទូទៅ។ ករណីទីពីរ បទពិសោធន៍កុប្បកម្មប្រឆាំងថៃក្នុងឆ្នាំ២០០៣ ចង្អុលបង្ហាញឱ្យឃើញលទ្ធភាពនៃការកើតមានឡើងនូវអស្ថេរភាពដែលជម្រុញដោយមូលហេតុនយោបាយ។[៧០]

---

[៦៩] បុព្វកថា *សេចក្តីសម្រេចអនុម័តដោយមហាសន្និបាត - ការជំនុំជម្រះខ្មែរក្រហម* GA Res A/RES/57/228 ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៣។

[៧០] John Aglionby "ថៃផ្តាច់ទំនាក់ទំនងជាមួយប្រទេសកម្ពុជា បន្ទាប់ពីមានអំពើកុបកម្ម" *អ្នកគ្រប់គ្រង* ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ២០០៣ (C11/11 ឧបសម្ព័ន្ធ ក ឯកសារភ្ជាប់ លេខ ក ១៥)។ "មន្ត្រីការទូតថៃវិលត្រឡប់ចូលប្រទេសកម្ពុជាវិញ" *ព័ត៌មាន BBC* ផ្សាយថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៣ (C11/11 ឧបសម្ព័ន្ធ ក ឯកសារភ្ជាប់ លេខ ក ១៦)។ "ប្រទេសកម្ពុជាធ្វើការសុំទោសចំពោះបញ្ហាកុបកម្ម" *CNN.com* ផ្សាយថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៣ (C11/11 ឧបសម្ព័ន្ធ ក ឯកសារភ្ជាប់ លេខ ក ១៧)។ Michael Flint *ការវាយតម្លៃលើកម្មវិធីប្រទេស DFID ការសិក្សាប្រទេសៈ កម្ពុជាឆ្នាំ១៩៩៧ - ឆ្នាំ២០០៣* ទីក្រុងឡុងដ៍ៈ នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិរបស់ចក្រភពអង់គ្លេស ឆ្នាំ២០០២ *ទំព័រទី ៤* (C11/11 ឧបសម្ព័ន្ធ ក ឯកសារភ្ជាប់ លេខ ក ១៨)។ អង្គការតាមដានសិទ្ធិមនុស្ស និងអង្គការលើកលែងទោសអន្តរជាតិ "ប្រទេសកម្ពុជាៈ សេរីភាពក្នុងការបញ្ចេញមតិរងការ

១១៧. អង្គហេតុដែលបានលើកឡើងខាងលើ អាចបង្ហាញថា ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន អាចនឹងធ្វើឱ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ យ៉ាងពិតប្រាកដ។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ន គឺជាវិធានការមួយចាំបាច់ដើម្បីរក្សាសណ្ដាប់ធ្នាប់សាធារណៈ។

## VII. ការដាក់ក្នុងមន្ទីរពេទ្យ ជាទម្រង់នៃការឃុំខ្លួនមួយបែបផ្សេង

១១៨. សហមេធាវីបានលើកឡើង នៅក្នុងសារណាបណ្ដឹងឧទ្ធរណ៍ថា សហមេធាវីការពារក្ដីមិនសុំការដោះលែងជនត្រូវចោទឡើយ ប៉ុន្តែខ្លួនស្នើសុំទម្រង់នៃការឃុំខ្លួនមួយបែបផ្សេងវិញ។ យើងឃើញមានការលើកឡើងអំណះអំណាងតវ៉ាថា ទម្រង់នៃការឃុំខ្លួនមួយបែបនេះ គួរត្រូវអនុញ្ញាត ដោយសារស្ថានភាពសុខភាពរបស់ជនត្រូវចោទ នាពេលបច្ចុប្បន្ន។ យោងតាមមេធាវីការពារក្ដី ជនត្រូវចោទគួរដាក់ឱ្យស្ថិតនៅក្នុងមន្ទីរពេទ្យជាមុនសិន និងបន្ទាប់មកជនត្រូវចោទគួរដាក់ឱ្យជាប់ឃុំនៅក្នុងផ្ទះ នៅពេលដែលសុខភាពរបស់គាត់ មានលក្ខណៈប្រសើរឡើង។

១១៩. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា វិធានផ្ទៃក្នុងមិនមានចែងជាក់លាក់អំពីទម្រង់នៃការឃុំខ្លួនបែបនេះឡើយ។

១២០. ប៉ុន្តែ វិធាន ៦៥(១) នៃវិធានផ្ទៃក្នុងចែងថា ជនត្រូវចោទអាចត្រូវបានគេដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ក្រោមលក្ខខណ្ឌមួយចំនួនចាំបាច់ដើម្បីធានាវត្តមានរបស់ជនត្រូវចោទក្នុងអំឡុងពេលដំណើរការនីតិវិធី និងដើម្បីការពារបុគ្គលដទៃ។ ដូច្នេះ អង្គបុរេជំនុំជម្រះនឹងធ្វើការបកស្រាយសំណើរបស់សហមេធាវីការពារក្ដីសុំទម្រង់នៃការឃុំខ្លួនមួយបែប

---

វាយប្រហារ" ចេញផ្សាយថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ (C11/11 ឧបសម្ព័ន្ធ ក ឯកសារភ្ជាប់លេខ ក)។ ក្រសួងការបរទេសសហរដ្ឋអាមេរិក ការិយាល័យកិច្ចការអាស៊ីបូព៌ា និងអាស៊ីប៉ាស៊ីហ្វិក *របាយការណ៍ជូនអង្គប្រជុំលើបញ្ហាកុបកម្មប្រឆាំងថៃនៅក្នុងប្រទេសកម្ពុជានៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៣* (C11/11 ឧបសម្ព័ន្ធ ក ឯកសារភ្ជាប់ លេខ ក ២៦)។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

00233045

E22 / I / 174



ផ្សេងនេះ គឺសំណើសុំឱ្យដោះលែង ដោយដាក់ឱ្យស្ថិតនៅក្នុងមន្ទីរពេទ្យ ឬដាក់ឱ្យជាប់ឃុំនៅក្នុងផ្ទះ។

១២១. អង្គបុរេជំនុំជម្រះយល់ឃើញថា នៅក្នុងរឿងក្តីនេះ លក្ខខណ្ឌនៃវិធាន ៦៣(៣)(ក) និងលក្ខខណ្ឌទាំងបីដូចមានចែងនៅក្នុងវិធាន ៦៣(៣)(ខ) បានបំពេញ ទោះបីលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌទាំងអស់នេះ អាចគ្រប់គ្រាន់ដើម្បីបញ្ជាក់អំពីការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នក៏ដោយ។ ចំនុចនេះមានន័យថា ការសម្រេចឃុំខ្លួនបណ្តោះអាសន្នជាវិធានការចាំបាច់ ដើម្បីធានាសន្តិសុខរបស់ជនត្រូវចោទ ដើម្បីធានាវត្តមានរបស់ជនត្រូវចោទក្នុងពេលដំណើរការក្តី និងរក្សាសណ្តាប់ធ្នាប់សាធារណៈ។ ក្នុងកាលៈទេសៈទាំងនេះ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ជនត្រូវចោទមិនអាចដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការបានឡើយ ដោយសារភាពចាំបាច់ក្នុងការសម្រេចឃុំខ្លួនបណ្តោះអាសន្ន មានអាទិភាពជាងលក្ខខណ្ឌទាំងឡាយដែលជនត្រូវចោទស្នើឡើង។

១២២. ទោះបីជាជនត្រូវចោទត្រូវបានអនុញ្ញាតឱ្យដាក់ឃុំនៅក្នុងមន្ទីរពេទ្យ ឬដាក់ឱ្យជាប់ឃុំនៅក្នុងផ្ទះក៏ដោយ យើងអាចមើលឃើញថា ហានិភ័យខ្ពស់អាចកើតមានចំពោះសុវត្ថិភាពផ្ទាល់ខ្លួនរបស់ជនត្រូវចោទ។ ជនត្រូវចោទនឹងតម្រូវឱ្យមកបង្ហាញខ្លួននៅ អ.វ.ត.ក នៅក្នុងពេលផ្សេងៗគ្នា ដែលធ្វើឱ្យមានការលំបាកដល់ការធានាចំពោះសុវត្ថិភាពផ្ទាល់ខ្លួនរបស់គាត់ ក្នុងពេលធ្វើដំណើរពីមន្ទីរពេទ្យ ឬផ្ទះរបស់គាត់មកកាន់អង្គជំនុំជម្រះ ដើម្បីមកចូលរួមក្នុងសវនាការជាសាធារណៈ ដែលបានកំណត់។

១២៣. គ្មានភស្តុតាងដែលជាតម្រូវការបន្ទាន់នៃការឃុំខ្លួនក្នុងមន្ទីរពេទ្យក្នុងរយៈពេលយូរឡើយ ហើយមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ហាក់ដូចជាបានបំពាក់នូវសម្ភារៈនិងឧបករណ៍ត្រឹមត្រូវសម្រាប់ផ្តល់ជំនួយផ្នែកវេជ្ជសាស្ត្រ ដូចដែលបានទាមទារ។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00233046

E22/I/74

០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៣)

## ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទៈ

១) បណ្ដឹងឧទ្ធរណ៍អាចទទួលយកបានតាមទម្រង់។

២) សហចៅក្រមស៊ើបអង្កេត បានអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួនត្រឹមត្រូវ ក្នុងការចេញដីកាសម្រេចឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ន។

៣) ការឃុំខ្លួនបណ្ដោះអាសន្ននៅតែជាវិធានការចាំបាច់មួយ ដោយផ្អែកលើមូលដ្ឋានដូចដែលបានរៀបរាប់ខាងលើ។

៤) តម្កល់ដីកាឃុំខ្លួនរបស់សហចៅក្រមស៊ើបអង្កេត ហើយមូលហេតុដែលបញ្ជាក់ក្នុងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបានជំនួសដោយមូលហេតុដែលបានបញ្ជាក់ក្នុងសាលដីកានេះ។

៥) បដិសេធចោលសំណើសុំឃុំខ្លួននៅក្នុងមន្ទីរពេទ្យ ដែលជាជម្រើសមួយបែបផ្សេងចំពោះការឃុំខ្លួន។

៦) បដិសេធចោលបណ្ដឹងឧទ្ធរណ៍។

សាលដីកានេះបិទផ្លូវតវ៉ា អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង។

សាលដីកានេះ **ប្រកាសជាសាធារណៈ** ដោយអង្គបុរេជំនុំជម្រះ នៅចំពោះមុខជនត្រូវចោទ និងសហមេធាវីខ្មែរ របស់ជនត្រូវចោទ។

**ភ្នំពេញ, ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨**

**អង្គបុរេជំនុំជម្រះ**

**ប្រធាន**

Rowan DOWNING **ន័យ ថុល** Katinka LAHUIS **ហួត វុធី** **ប្រាក់ គីមសាន**

**ក្រឡាបញ្ជីសវនាការ**

**ដួន សុរាសី** Dirk Jan LAMAN